BMI0060

# សម្ភាសន៍ជាមួយឈ្មោះ សៅ ហ៊ឹយ ភេទស្រី អាយុ៥២ឆ្នាំ

មុខងាររដ្ឋខ្មែរក្រហម“ពេទ្យ”

មុខងារបច្ចុប្បន្ន“កសិករ”

ស្រុកកំណើតនៅភូមិបត់ ឃុំបត់ ស្រុកអន្លង់វែង ខេត្តសៀមរាប

រស់នៅភូមិវាលហាត់ ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។

ថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១០

សម្ភាសន៍ដោយៈ សោម ប៊ុនថន

០១:០៩:០៧

៤២ទំព័រ

ប៊ុនថនៈ ចឹងជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះមីង?

ហ៊ឹយៈ ខ្ញុំឈ្មោះ សៅ ហ៊ឹយ ។

ប៊ុនថនៈ មីងអាយុប៉ុន្មានហើយ?

ហ៊ឹយៈ ខ្ញុំអាយុ៥២ ។

ប៊ុនថនៈ មីងមានស្រុកកំណើតនៅណាដែរ?

ហ៊ឹយៈ ខ្ញុំមានស្រុកកំណើតនៅអន្លង់វែង ។

ប៊ុនថនៈ ភូមិ?

ហ៊ឹយៈ ភូមិបត់ ឃុំបត់ ស្រុកអន្លង់វែង ។

ប៊ុនថនៈ ខេត្តសៀមរាប?

ហ៊ឹយៈ ចាស! ខេត្តសៀមរាប ។

ប៊ុនថនៈ មីងមានបងប្អូនប៉ុន្មាននាក់?

ហ៊ឹយៈ ខ្ញុំមាន៦ នាក់ ។

ប៊ុនថនៈ មីងកូនទីប៉ុន្មាន?

ហ៊ឹយៈ ខ្ញុំកូនទី២ ។

ប៊ុនថនៈ ប្រុសប៉ុន្មានស្រីប៉ុន្មានមីង?

ហ៊ឹយៈ ប្រុស៣ ស្រី៣ ។

ប៊ុនថនៈ ចុះឪពុកម្ដាយមីង?

ហ៊ឹយៈ ឪពុកម្ដាយខ្ញុំគេយកវ៉ៃចោលសម័យប៉ីផ្ដាំ ឆ្នាំ៧៨ ។

ប៊ុនថន: ចឹងសព្វទាំងពីរនាក់?

ហ៊ឹយៈ ស្លាប់តែឪពុកទេ គេយកទៅវ៉ៃចោល ។

ប៊ុនថនៈ ស្លាប់ឆ្នាំ៧៨?

ហ៊ឹយៈ ចាស!៧៨ថ្ងៃទី១០ ។

ប៊ុនថនៈ ចឹងម្ដាយ?

ហ៊ឹយៈ ម្ដាយនៅរាល់ថ្ងៃ ។

ប៊ុនថនៈ ចឹងគាត់អាយុប៉ុន្មានហើយ?

ហ៊ឹយៈ ម្ដាយខ្ញុំអាយុ៧៧ ។

ប៊ុនថនៈ គាត់នៅសៀមរាបឬនៅណា?

ហ៊ឹយៈ គាត់នៅអង្គរជុំ គាត់ទើបតែទៅពីនេះវិញ ។

ប៊ុនថនៈ បាទៗចឹងមីងមានបានរៀនទេ?

ហ៊ឹយៈ មីងមិនបានរៀនទេ មីងរៀនសាលាវត្តដល់ពេលហើយទៅ កាលនៅក្មេងឆោតណាស់ក្មួយ ។

ប៊ុនថនៈ បាទ ។

ហ៊ឹយៈ មីងកាលហ្នឹងរៀនគ្រូវត្ត គ្រូលោកណាស់ ដល់មីងហ្នឹងទៅបេះពន្លាក់យកពិតលោកគ្រូ ដល់ចូលសាលាក្រោយគេទៅ លោកគ្រូវ៉ៃបាក់បន្ទាត់ អាបន្ទាត់យើងពីសង្គមអាបន្ទាត់ធំនោះ ។

ប៊ុនថនៈ បន្ទាត់វែង?

ហ៊ឹយៈ ចាស!បន្ទាត់វែងបួនជ្រុង ។

ប៊ុនថនៈ បាទ ។

ហ៊ឹយៈ វ៉ៃទៅបាក់បន្ទាត់ដល់ហើយបងខ្ញុំនៅរាល់ថ្ងៃហ្នឹងថាអូនអើយមិនបាច់រៀនទេ ហើយខ្ញុំឈឺទៀត ឈឺឡើងរុះសក់អត់បានរៀនទេ លូង់ដល់សព្វថ្ងៃអត់មានចេះអក្សរទេក្មួយ ។

ប៊ុនថនៈ បាទ ។

ហ៊ឹយៈ មីងអត់មានចេះមួយអង្គទេ ។

ប៊ុនថនៈ មីងខ្លាចគ្រូ?

ហ៊ឹយៈ វាឈឺៗឈឺឡើងជ្រុះសក់នោះ ឈឺឡើងមិនដឹងអីនោះ លោកគ្រូមិនដឹងលោកគ្រូវ៉ៃក្បាលនោះ ។

ប៊ុនថន៖ បាទ ។

ហ៊ីយ៖ បើវិបាតដៃមិនអីទេ មីងចូលរៀនបានតែដល់លោកគ្រូវិរ៉ៅ ចុះគ្រូលោកនោះ ។

ប៊ុនថន៖ កាច?

ហ៊ីយ៖ គ្រូពីសង្គមចាស់នោះ លោកគ្រូកាចឈ្មោះ លោកគ្រូឌៀបលោកគ្រូកាចណាស់ ។

ប៊ុនថន៖ បាទ ។

ហ៊ីយ៖ ដល់ហើយឈឺ កាលពីសង្គមចាក់ថ្នាំក៏វាមិនថ្លៃប៉ុន្មានដែរ យើងប្រើក្រដាសគោមួយនឹម នោះ ។

ប៊ុនថន៖ ក្រដាសរូបគោមួយនឹម?

ហ៊ីយ៖ ចាស!លុយពីសង្គមចាស់នោះណាស់ ។

ប៊ុនថន៖ បាទ ។

ហ៊ីយ៖ ចាស!កាលនោះចាក់ប្រហែលប៉ុន្មានទេ ពីសង្គមចាស់មាសមួយជីតែ៣០០រៀលទេ ។

ប៊ុនថន៖ បាទ ។

ហ៊ីយ៖ មិនមានថ្លៃដូចសព្វថ្ងៃទេ មាសតែមួយជី៣០០ទេ ៣០០កាលនោះបើអ្នកពិបាករកមិន បានទៀត គោមួយតែ១០០០ហ្នឹងមហាស្អាត ។

ប៊ុនថន៖ បាទ!ចឹងលុយថ្លៃ?

ហ៊ីយ៖ ចាស!លុយថ្លៃណាស់ពីសង្គមចាស់

ប៊ុនថន៖ បាទ ។

ហ៊ីយ៖ លុយថ្លៃបំផុត ដល់ក្រោយមកមីងឈប់ ដល់ជាពីឈឺហ្នឹងមីងទៅរៀនហ្នឹងគេទៀតទៅឲ្យ តែចូលរៀនដឹងតែឈឺតែម្តង ។

ប៊ុនថន៖ បាទ ។

ហ៊ីយ៖ ចឹងបានមីងល្ងង់ដល់សព្វថ្ងៃហ្នឹង ។

ប៊ុនថន៖ ចឹងឈឺទៅរៀនម្តងទៀតរៀនបានយូរដែរ?

ហ៊ីយ៖ ចូលបានមួយថ្ងៃឈឺទៀត ឈឺហ្នឹងប្រហែលជាខ្លាចគ្រូមើលទៅ ។

ប៊ុនថន៖ សើច... ។

ហ៊ីយ៖ សើច...ប្រហែលជាខ្លាចគ្រូខ្លាំងអត់ចេះទេក្មួយ ។

ប៊ុនថន៖ បាទ ។

ហ៊ីយ៖ មិនចេះទេ បើរឿងអីផ្សេងៗមិនជាចាញ់គេប៉ុន្មានទេ ។

ប៊ុនថន៖ ចឹងក៏ឈប់រៀនទៅ?

ហ៊ីយៈ ចាស!ឈប់រៀនទៅ ។

ប៊ុនថនៈ ឈប់រៀនហើយមីងធ្វើអីទៅ?

ហ៊ីយៈ ឈប់រៀនហ្នឹងក៏នៅផ្ទះទៅមានធ្វើអីពីដើមមានតែកិនស្រូវព្រោះចាស់ៗកាលជំនាន់ពីដើមហ្នឹងគាត់ថា ខ្ញុំឲ្យឪពុកខ្ញុំយកស្រូវទៅដាក់ម៉ាស៊ីន ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ តែឪពុកខ្ញុំប្រាប់ថា កូនគេមិនឲ្យយកស្រូវដាក់ម៉ាស៊ីនទេ ហូបទៅស្ពឹកដៃស្ពឹកជើង គាត់ឲ្យខ្ញុំហាលគាត់ឲ្យខ្ញុំទិញថ្បាលកិនធ្វើអំពីឬស្សីយើងថ្បាលកិន ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ ឲ្យយើងកិនទៅ ។

ប៊ុនថនៈ យ៉ាងម៉េចនិយាយថាហូបទៅស្ពឹកដៃ?

ហ៊ីយៈ អង្ករដាក់ម៉ាស៊ីនហ្នឹងវាអស់ជាតិផ្អែម ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ តែឲ្យយើងស្រិតទៅឲ្យយើងកាប់ទៅចាស់ពីដើមហៅស្រិតណាស់ ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ ស្រិតអង្ករបុកអង្ករបុកស្រូវអីចឹងណាស់ ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ តែអាហ្នឹងហូបមិនចេះស្ពឹកដៃស្ពឹកជើងទេ បើសិនជាយើងហូបអង្ករដាក់ម៉ាស៊ីនហ្នឹងវាអស់ជាតិនៅតែស្ងួទៅវាស្ពឹកដៃស្ពឹកជើង ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ តែតាមដានទៅវាពិតមែន ដូចសព្វថ្ងៃមានជាតិគីមីអីច្រើនណាស់ចឹងហើយចេះតែមានមេរោគពោះវៀនក្រពះ កាលពីមុនមិនមានទេ ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ ខ្ញុំតាមដានមើលកាលមុននិងក្រោយវាខុសគ្នា ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ តែសង្គមសព្វថ្ងៃហ្នឹងវាជឿនលឿនណាស់ យើងពីដើមអត់មានអីជឿនលឿនទេ ធ្វើស្រែធ្វើចំការតាមធម្មតាទៅហើយមិនមានជាអ្នកអត់ឃ្លានអីទេ ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ ដល់សម័យយើងឥឡូវជាសម័យកំព្យូទ័រវិឡ្លន៍លឿនហើយ ។

ប៊ុនថន៖ ចឹងឪពុកម្ដាយអ្នកមីង?

ហ៊ីយ៖ ធ្វើតែស្រែទេ ហើយឪពុកធំខ្ញុំហ្នឹងគាត់ពាក់សក្តិ៤កន្ទះពីសង្គម ។

ប៊ុនថន៖ បាទ ។

ហ៊ីយ៖ ឪពុកធំខ្ញុំហ្នឹងពាក់សក្តិ៤កន្ទះ ។

ប៊ុនថន៖ ពាក់សក្តិ៤កន្ទះហ្នឹងខាងណា?

ហ៊ីយ៖ ខាងសម្ដេច គាត់ទាហានពីសង្គមចាស់ ។

ប៊ុនថន៖ បាទ ។

ហ៊ីយ៖ គេយកវៃចោលដែរ គេយកវៃចោលនៅភ្នំវ៉ារិននោះ ។

ប៊ុនថន៖ នៅវ៉ារិន?

ហ៊ីយ៖ ចាស!ស្រុកវ៉ារិននៅសៀមរាបនោះណាស់ គេយកវៃចោលទាំងអស់មិនមានទេក្មួយមីង គេវៃចោលដាច់ពូជឡើងពីរគ្រួសារ ។

ប៊ុនថន៖ បាទ!ចឹងមីងនៅជាមួយឪពុកម្ដាយយូរទេ?

ហ៊ីយ៖ ខ្ញុំបែកគាត់តាំងពី៧២ រហូតដល់សព្វថ្ងៃនេះ តែពេលផ្ដាច់ខ្លួនហើយបានទៅរកគាត់ ។

ប៊ុនថន៖ ៧២ហ្នឹងមីងទៅណាវិញមីង?

ហ៊ីយ៖ ៧២ធ្វើបដិវត្ត ចូលសិល្បៈចឹងទៅ គេសុំពីសិល្បៈចូលពេទ្យចឹងទៅ ។

ប៊ុនថន៖ ចឹងបានធ្វើច្រើនកន្លែង?

ហ៊ីយ៖ ចាស! ចូលមកនៅពេទ្យហ្នឹងចង់ព្យាបាលហ្នឹងគេ គេមិនឲ្យព្យាបាលទេមីងនៅតូចនោះ ។

ប៊ុនថន៖ បាទ ។

ហ៊ីយ៖ តែគេឲ្យរៀនខាងឆ្មប ដល់រៀនខាងឆ្មបក្មួយប៉ះតែកូនពងទេ ។

ប៊ុនថន៖ កូនពង?

ហ៊ីយ៖ ចាស!កូនពង មីងរៀនដាក់ស្តែងតែម្ដងមីងអត់មានរៀនតាមឯកសារទេ រៀនដាក់ស្តែងចាប់ពីបមកគេឲ្យបង្កើតភ្លាម ។

ប៊ុនថន៖ ចឹងរាល់ថ្ងៃហ្នឹងមីងចេះដែរ?

ហ៊ីយ៖ រាល់ថ្ងៃមីងចេះមីងនៅឆ្មបភូមិ ។

ប៊ុនថន៖ នៅឆ្មបភូមិ?

ហ៊ីយ៖ ចាស! ។

ប៊ុនថន៖ នៅតាំងពីហ្នឹងមក?

ហ៊ីយ៖ ចាស!ទើបចូលបានមួយឆ្នាំពីរឆ្នាំ ។

ប៊ុនថនៈ ចឹងកាលឆ្នាំ៧២ហ្នឹងមីងបែកពីផ្ទះហ្នឹងមីងធ្វើអីវិញ?

ហ៊ីយៈ ធ្វើសិល្បៈរាំសិល្បៈជាមួយបងសេងហ្នឹងនៅខត្តរហ្នឹង ។

ប៊ុនថនៈ បាទ!កាលហ្នឹងគេជ្រើសរើស?

ហ៊ីយៈ កាលហ្នឹងគេជ្រើសរើសតាមភូមិ ។

ប៊ុនថនៈ ចឹងសែកមិញមានឃើញរូបនៅក្នុងហ្នឹងទេ?

ហ៊ីយៈ អត់ទេ មិនឃើញ ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ នៅសិល្បៈ ។

ប៊ុនថនៈ ជ្រើសរើសចូល?

ហ៊ីយៈ ចាស ។

ប៊ុនថនៈ តែបែកពីផ្ទះទេ កាលហ្នឹង?

ហ៊ីយៈ បែកតើគេឲ្យទៅហាត់នៅដុបនោះក្នុងព្រៃ ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ ចាស!ឲ្យហាត់អត់មានឲ្យមកផ្ទះទេ មួយសិល្បៈស្រុកពីរសិល្បៈភាគ ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ សិល្បៈភាគហ្នឹងសិល្បៈតំបន់ គេចែកគ្នាហើយពេលយើងប្រឡងដូចសព្វថ្ងៃចឹងណាស់ ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ ដូចថាសិល្បៈស្រុកមកប្រឡងជាមួយសិល្បៈតំបន់ ។

ប៊ុនថនៈ ចឹងសិល្បៈភាគហ្នឹងធំជាងគេ?

ហ៊ីយៈ ចាស!ហើយដល់ពេលយើងប្រឡងហើយម្នាក់ម្តងៗគេធ្វើរោងចឹងទៅណាស់ ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ ពេលយើងរាំសិល្បៈចឹងទៅគេធ្វើរោងទៅគេដោតស្លឹកជ្រៃៗខាងៗសរសរចឹងណាស់ ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ បើមានកងទ័ពអីមកជួបជុំជប់លៀងគ្នាចឹងទៅ ។

ប៊ុនថនៈ ចឹងគេប្រឡងយកលេខមួយលេខ២អីមីង?

ហ៊ីយៈ មិនមានទេ ពីណាឲ្យពន្ទុទេគ្រាន់ថា អ្នកណាធ្វើស្អាតមិនដូចឥឡូវទេ ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ គ្រាន់តែយើងប្រឡងឃើញស្អាតហ្នឹង កាលហ្នឹងគេហៅអង្គការណាក្លួយ ។

ប៊ុនថន៖ បាទ ។

ហ៊ីយ៖ គេថាក្រុមនេះធ្វើបានស្អាតមិនមានពីណាឲ្យពន្ធុដូចជាសព្វថ្ងៃនេះទេ ។

ប៊ុនថន៖ បាទ ។

ហ៊ីយ៖ ធ្វើឲ្យបានស្អាត ការពិតទៅដូចជាឲ្យពន្ធុដូចគ្នា កាលហ្នឹងគេអត់មានប្រើភាសាហ្នឹងណាស់ ។

ប៊ុនថន៖ បាទ ។

ហ៊ីយ៖ ហើយគ្រាន់ថាក្រុមហ្នឹងធ្វើបានស្អាត មានតែក្រុមហ្នឹងអាចឡើងទៅភាគបាន ។

ប៊ុនថន៖ បាទ ។

ហ៊ីយ៖ ចឹងយើងរើសពីហ្នឹងទៅ យើងប្រឡងស្អាតហើយយើងចូលទៅភាគទៅ ។

ប៊ុនថន៖ ចឹងភាគហ្នឹងធំជាងគេ?

ហ៊ីយ៖ ចាស!បក្សភូមិភាគនោះ ។

ប៊ុនថន៖ ចឹងមីងមានបានចូលទៅភូមិភាគទេ?

ហ៊ីយ៖ ចូលខ្ញុំនៅជាមួយបងសេងបក្ខភូមិភាគហ្នឹង នៅខាងតំបន់កាលហ្នឹងគេហៅតំបន់៤ចឹងឯង តំបន់អីទេ កាលហ្នឹងភ្លេចអស់ហើយវាយូរហើយ ។

ប៊ុនថន៖ តែខាងភាគហ្នឹងគាត់គ្រប់គ្រងទាំងអស់តែម្ដង?

ហ៊ីយ៖ ចាស ។

ប៊ុនថន៖ ចឹងខាងសិល្បៈហ្នឹងគេអត់មានជ្រើសរើសរកអ្នកស្អាតអ្នកពូកែអីទេ?

ហ៊ីយ៖ មិនទេ ឲ្យតែធ្វើកាយវិការអីត្រូវរាំស្អាតអីចេះតែទៅណាស់ ។

ប៊ុនថន៖ បាទ ។

ហ៊ីយ៖ ចេះតែទៅមុខទៀតទៅ ។

ប៊ុនថន៖ ចឹងមីងចូលដំបូងសិល្បៈស្រុក?

ហ៊ីយ៖ ខ្ញុំចូលដំបូងសិល្បៈស្រុក នៅស្រុកហ្នឹងគេឲ្យខ្ញុំដឹកយាយ គេថាគេច្រៀងបាតុកម្ម១១ វិច្ឆិកានោះ ។

ប៊ុនថន៖ បាទ ។

ហ៊ីយ៖ ដល់ហើយច្រៀងដឹកយាយហ្នឹងឯង ហើយយាយហ្នឹងកាន់ឈើច្រាត់ឃ្នីក១ៗទៅអាចៅហ្នឹង ចេះតែដឹកទៅណាស់ ។

ប៊ុនថន៖ បាទ ។

ហ៊ីយ៖ ដឹកទៅរាំបាតុកម្មអីចេះចុះចេះមួយៗៗចឹងណាស់ ។

ប៊ុនថន៖ បាទ ។

ហ៊ឺយ៖ កាលហ្នឹងបាស់បោលខ្មែរសនោះ ម៉ាជំនាន់ហ្នឹងនោះ ។

ប៊ុនថន៖ ឡើងសម្ដែងលើឆាកឲ្យគេមើល?

ហ៊ឺយ៖ ចាស! ឡើងសម្ដែងលើឆាក ។

ប៊ុនថន៖ ចឹងមីងមានភ័យទេពេលហ្នឹង?

ហ៊ឺយ៖ អត់មានភ័យអីទេ ធម្មតាកាលហ្នឹងមិនចេះអេនចេះខ្មាស់ទេ កាលហ្នឹង ។

ប៊ុនថន៖ បាទ ។

ហ៊ឺយ៖ និរសារអន់អាចអីណាណីតាពាសទៅណាស់ ។

ប៊ុនថន៖ បាទ ។

ហ៊ឺយ៖ ច្រៀងរាំទៅ ចេះតែរាំរ៉ែកទៅមិនទៅគិតខ្វល់ខ្វាយ នៅក្មេងមិនទៅគិតថាលំបាកនឿយហត់អីអត់ទេ ។

ប៊ុនថន៖ បាទ! ច្រើនគ្នាទេមីង?

ហ៊ឺយ៖ ច្រើន សិល្បៈច្រើនដល់ពេលយើងសម្ដែងរាំចេះមួយៗ ទៅដូចជាក្លាយឯងជាប់ចឹងទៅទៅនៅភាគចឹងទៅ ។

ប៊ុនថន៖ បាទ ។

ហ៊ឺយ៖ អត់មានឲ្យនៅក្នុងនេះទេ ដកឲ្យទៅនៅនោះទៅគេជម្រើសរកតែនាក់រាំជាប់អីចឹង ។

ប៊ុនថន៖ បាទ ។

ហ៊ឺយ៖ ឧទាហរណ៍ដូចជាកង័ទ័ពយើងវ៉ៃដាច់ត្រង់ណាដូចថាវ៉ៃដាច់ម៉ាឡៃចឹងទៅ គេយកកង់ទ័ពទៅជប់លៀងរាំរ៉ែកឲ្យមើលចឹងណាស់ ។

ប៊ុនថន៖ បាទ ។

ហ៊ឺយ៖ តែប៉ុណ្ណឹងទេ កាលហ្នឹងនោះមិនមានអីគួរអស្ចារ្យទេ ដូចថាយើងឈរពីរជួរចឹងកង់ទ័ពដើរកណ្ដាលយើងចាប់ដៃតែប៉ុណ្ណឹងទេ ។

ប៊ុនថន៖ បាទ ។

ហ៊ឺយ៖ មិនមានអីអស្ចារ្យប៉ុន្មានទេ ថាសុខសប្បាយបងអើយពីអើយចេះៗ ទៅប៉ុណ្ណឹងឯង ។

ប៊ុនថន៖ បាទ ។

ហ៊ឺយ៖ ហើយសម័យហ្នឹងបើមិនអនុញ្ញាតិឲ្យយើងសួរសុខទុក្ខក៏យើងមិនហ៊ានចាប់ដៃគ្នាដែរ ។

ប៊ុនថន៖ បាទ ។

ហ៊ឺយ៖ មិនហ៊ានចាប់ទេ ជំនាន់ហ្នឹងនោះ មិនមែនឡិកឡូក់បានដូចយើងរាល់ថ្ងៃហ្នឹងណា ។

ប៊ុនថន: និយាយលេងសើចបានទេ?

ហ៊ីយៈ អត់ទេៗ អត់មានទៅនិយាយអីបានទេ ។

ប៊ុនថន: ចឹងមីងមានប្រុសៗទេក្រុមសិល្បៈ?

ហ៊ីយៈ មាន ។

ប៊ុនថន: លាយគ្នា?

ហ៊ីយៈ មានលាយគ្នាចម្រុះគ្នាដូចតែយើងរាល់ថ្ងៃចឹងដែរ ។

ប៊ុនថន: តែនៅផ្សេងគ្នា?

ហ៊ីយៈ នៅផ្សេងគ្នា មានរោងវែងចឹងទៅ គេនៅរោងគេយើងនៅរោងយើង យប់ឡើងយើងហាត់ម៉ោង១១ម៉ោង១២យើងដេកទៅ ។

ប៊ុនថន: មានគ្រូបង្ហាត់ទេ?

ហ៊ីយៈ មាន កាលហ្នឹងមាន ។

ប៊ុនថន: ចឹងមីងនៅសិល្បៈស្រុកហ្នឹងនៅកន្លែងណាវិញ?

ហ៊ីយៈ សិល្បៈស្រុកហ្នឹងខ្ញុំនៅម៉ាដួលព្រៃរំដួលហ្នឹង ព្រៃរំដួលស្រុកអង្គជុំហ្នឹង ។

ប៊ុនថន: បាទ ។

ហ៊ីយៈ នៅភូមិរំដួលហ្នឹង ។

ប៊ុនថន: ចឹងមីងមានទៅមកផ្ទះទេ?

ហ៊ីយៈ អត់ដែលទៅមកទេ គេមិនឲ្យដើរតែម្ដង ។

ប៊ុនថន: ចឹងបែកពីផ្ទះហើយកាលហ្នឹង?

ហ៊ីយៈ តែចូលកន្លែងអង្គការហើយអង្គការមិនឲ្យចូលផ្ទះទេ ដេកផ្ទះដេកអីអត់ទេ ។

ប៊ុនថន: បាទ ។

ហ៊ីយៈ មិនឲ្យសម្រាក់មកផ្ទះអីចេញចូលមកឪពុកម្ដាយអីអត់ទេ តែគ្រាន់ថាចង់មកលេងចឹងសុំច្បាប់មកបាន ។

ប៊ុនថន: បាទ ។

ហ៊ីយៈ ម៉ោងប៉ុន្មានអីប៉ុន្មានតែមកដេកអត់បានទេ ព្រោះអីយើងកំពង់តែហាត់ ។

ប៊ុនថន: បាទ!ចឹងកាលមីងមកសិល្បៈភាគហ្នឹងបែកពីភូមិរំដួលហើយ?

ហ៊ីយៈ បែកហើយខ្ញុំទៅនៅដូនអែមនោះ ។

ប៊ុនថន: ដូនអែម?

ហ៊ីយៈ ចាស!ដូនអែមនៅព្រៃជីដុសនោះ កាលនោះកប៉ាល់វាខស្សរាធ្វើទម្លាក់គ្រាប់ទម្លាក់អី ។

ប៊ុនថន: បាទ ។

ហ៊ីយ: ចឹងយើងនៅតាមដុសទៅតែសិល្បៈហាត់ជាប់ តែកាលជំនាន់ហ្នឹងទាហានលន់ នល់អត់មានដើររាស់ដូចកាលសម័យយួននេះទេ ។

ប៊ុនថន: បាទ ។

ហ៊ីយ: អត់ទេ មានតែដើងអាកាសទេដែលហោះហើរបានណាស់ ។

ប៊ុនថន: បាទ ។

ហ៊ីយ: តែកាលសម័យហ្នឹងអត់មានដើររាស់អីបាន ដេកមិនបានអីមិនបានក្នុងព្រៃអត់ទេ អត់មាន ។

ប៊ុនថន: នៅកន្លែងណាកន្លែងហ្នឹង?

ហ៊ីយ: នៅកន្លែងណាកន្លែងហ្នឹងអត់មានពិបាក ។

ប៊ុនថន: ចឹងមីងនៅខាងសិល្បៈស្រុកហ្នឹងនៅខាងអីវិញ?

ហ៊ីយ: មីងហ្នឹង ។

ប៊ុនថន: បាទ ។

ហ៊ីយ: កាលហ្នឹងនៅតែស្រុកវ៉ារិនដដែលហ្នឹង ។

ប៊ុនថន: វ៉ារិនដដែល?

ហ៊ីយ: ចាស ។

ប៊ុនថន: ភាគនៅហ្នឹង?

ហ៊ីយ: ចាស! នៅក្នុងដុកអត់មាននៅក្នុងភូមិអត់ទេ យើងនៅតែក្នុងដុកទេ យើងធ្វើឈើបួនជ្រុងចឹងទៅយើងដាក់សាក់កាដូចឹងទៅ ។

ប៊ុនថន: បាទ ។

ហ៊ីយ: ពេលគេហាត់សិល្បៈចឹងទៅយើងកាប់ស្លឹកឈើដាក់រង្វើលចឹងទៅហាត់ក្នុងទឹកចឹងទៅ ។

ប៊ុនថន: ហាត់ក្នុងទឹកយ៉ាងម៉េចទៅមីង?

ហ៊ីយ: ហាត់ដើរកុំឲ្យព្រុណាស់ក្នួយ មិនឲ្យព្រួដេកដួាប់ៗអីទេ យើងហាត់ការពារកប៉ាល់នោះយើងធ្វើរង្វើលបួនជ្រុង យើងធ្វើរង្វើលមូលចឹងទៅយើងដោតស្លឹកឈើ ។

ប៊ុនថន: បាទ ។

ហ៊ីយ: ដោតៗវាទៅកុំឲ្យវាឃើញសាក់កាដូវ៉ាទម្លាក់គ្រាប់បែកមក ។

ប៊ុនថន: បាទ ។

ហ៊ីយ: ឬក៏ទម្លាក់ពុយសាំងមកលើយើង ។

ប៊ុនថន៖ ដុតនេះហ្នឹង?

ហ៊ីយ៖ ចាស!ដុតនេះកាលជំនាន់ហ្នឹងលំបាកណាស់ក្មួយនិយាយទៅវែងឆ្ងាយណាស់ ។

ប៊ុនថន៖ កាលហ្នឹងពូនៅជាមួយប្រធានសិល្បៈហ្នឹងឈ្មោះអីវិញ?

ហ៊ីយ៖ ឈ្មោះបងសេង ។

ប៊ុនថន៖ ពូសេង?

ហ៊ីយ៖ តែឥឡូវគេវៃចោលអស់ហើយស្លាប់អស់ហើយ បើមីងអីក៏ជាប់គុកដែរ ទើប៧៩បានដោះរួចមីងជាប់គុកដែលតើកាលជំនាន់ហ្នឹង គេចង់វៃចោលកុំតែបានពួកហេង សំរិន មករំដោះថ្ងៃ៧មករាហ្នឹង ។

ប៊ុនថន៖ បាទ ។

ហ៊ីយ៖ មិនមានរថក្រោះឡានអីស្រែកជ័យយោ! ថាម៉េចទេ សាមគ្គីសង្គ្រោះជាតិកម្ពុជាគេស្រែកថាម៉េចភ្លេចបាត់ហើយ ។

ប៊ុនថន៖ ចឹងមីងនេះហើយមីងរត់មកហ្នឹងទៀត?

ហ៊ីយ៖ ចាស! គិតទៅដើរចោលស្រុកនៅមិនបាន ។

ប៊ុនថន៖ ចឹងមីងនៅសិល្បៈហ្នឹងបានប៉ុន្មានឆ្នាំបានមីងចេញវិញ?

ហ៊ីយ៖ មីងនៅសិល្បៈដល់ឆ្នាំ៧៥ ។

ប៊ុនថន៖ ចឹងនៅសិល្បៈរហូត?

ហ៊ីយ៖ ចាស!ចេញពីសិល្បៈ៧៤ ដល់៧៥មីងនៅបន្ទពេទ្យរហូត ។

ប៊ុនថន៖ ៧៤ហ្នឹងធ្វើអីវិញមីង?

ហ៊ីយ៖ ៧៤នៅសិល្បៈដដែល ។

ប៊ុនថន៖ បាទ ។

ហ៊ីយ៖ ដល់៧៥ហ្នឹងមីងនៅពេទ្យរហូត ។

ប៊ុនថន៖ ដកមកខាងពេទ្យម្ដង?

ហ៊ីយ៖ ចាស!នៅតែពេទ្យឆ្មបរហូត ។

ប៊ុនថន៖ ខាងណាដក?

ហ៊ីយ៖ អង្គការហ្នឹងសុំយកមកណាស់ ។

ប៊ុនថន៖ បាទ ។

ហ៊ីយៈ	គេថាឃើញក្មេងនេះដូចឈ្លាសវៃចឹងទៅគេសុំគ្នាទៅណាស់ សុំទៅអត្តការហ្នឹងថាអញស្តាយណាស់មិនចង់ឲ្យមិត្តហ្នឹងទៅនេះទៅនោះ សុំទៅបានគេឲ្យមកបានខ្ញុំជាប់នៅតំបន់៥ចឹងមក ។

ប៊ុនថន:	បាទ ។

ហ៊ីយៈ	កាលពីមុនខ្ញុំនៅខាងខត្តរហ្នឹងទេ ។

ប៊ុនថន:	កាលហ្នឹងពីណាកាន់ខាងខត្តរ?

ហ៊ីយៈ	គណៈស្រុកគណៈភូមិភាគ ។

ប៊ុនថន:	បាទ ។

ហ៊ីយៈ	ដូចជាឈ្មោះស្អីណាទេ តែខ្ញុំភ្លេចអស់ហើយខ្ញុំមិនបានចងចាំទេ ដូចថាផ្លូវពិបាកច្រើនចឹងទៅវាភ្លេចអស់ការចងចាំ ចង់បំភ្លេចចោលសម័យហ្នឹងវាពិបាកប៉ុណ្ណាមីងហូបបបរប៉ុណ្ណាមីងវេទនាប៉ុណ្ណាហើយមីងឪពុកម្តាយឪពុកគេចាប់យកទៅវៃចោលក៏មិនបានដឹង មិនដឹងរឿងមិនដឹងរ៉ាវអី ។

ប៊ុនថន:	បាទ ។

ហ៊ីយៈ	ដល់បានមកជួបឪពុកម្តាយហ្នឹងក៏អស់ឪពុកហោវទៅ ខ្ញុំមិនចង់ចងចាំទេ ។

ប៊ុនថន:	បាទ!កាលគេដកមីងទៅហ្នឹងគេឃើញមីងឆ្លាតពូកែនិយាយធ្វើការយ៉ាងម៉េច?

ហ៊ីយៈ	ពូកែៗៗដូចថាយើងពូកែចងចាំចឹងទៅណាស់ ដល់ពេលហើយយើងចងចាំថាគេនិយាយអីមកយើងចាប់ទុកទៅ ចងចាំទុកទៅតែសព្វថ្ងៃមិនចងចាំទេ ។

ប៊ុនថន:	បាទ ។

ហ៊ីយៈ	ភ្លេចភ្លាំងអស់ ព្រោះមីងឈឺដាក់ឈាមអស់ឡើងបីបួនលីតទៅភ្លេចការចងចាំអស់ហើយ ។

ប៊ុនថន:	បាទ!ចឹងកាលមីងមកខាងពេទ្យហ្នឹងមីងមកខាងតំបន់៥នេះវិញ?

ហ៊ីយៈ	ចាស ។

ប៊ុនថន:	មកច្រើនគ្នាទេមីង?

ហ៊ីយៈ	មកកាលហ្នឹងប្រហែលជា២០នាក់ តែផាប់អស់គេវៃចោលអស់មកនៅព្យាបាលអាំងត្រពាំងថ្មហ្នឹងគេវៃចោលធ្វើស្នូរអាងត្រពាំងថ្មហ្នឹងអស់រលីង បេះនៅតែមីងមួយគេចាប់យកមកដាក់គុកទៀត ថាយប់ហ្នឹងឯងគេយកទៅវៃចោល យប់ហ្នឹងឯងដែលហេង សរិនចូលដល់ គេឆ្លើយថារណសិរ្សសាមគ្គីសង្គ្រោះជាតិ ។

ប៊ុនថន:	បាទ ។

ហ៊ីយៈ បានគាត់ហ្នឹងមករំដោះចេញពីគុកអីចឹងទៅណាស់ បានជាមីងមានជីវិតរស់រៀនហ្នឹងកុំអីក៏មីងមិនបានរស់ដែរ ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ យ៉ាប់ដែរ ។

ប៊ុនថនៈ ចង់សួរពេទ្យនៅតំបន់៥ហ្នឹងមីងនៅម្តុំណាដែរ?

ហ៊ីយៈ មីងនៅស្វាយនេះ នៅសាលាកេលេសនេះ សាលារៀនសព្វថ្ងៃនៅលើភ្នំហ្នឹង ។

ប៊ុនថនៈ ស្វាយស៊ីសាផុនហ្នឹងម្ងង?

ហ៊ីយៈ ចាស!មន្ទីរពេទ្យគេនៅហ្នឹង ។

ប៊ុនថនៈ គេហៅពេទ្យតំបន់៥?

ហ៊ីយៈ ចាស!ពេទ្យតំបន់៥ បើអ្នកជំងឺធ្ងន់គេបញ្ជូនមកពេទ្យមង្គលបូរី ។

ប៊ុនថនៈ មង្គលបូរី?

ហ៊ីយៈ ចាស!បញ្ជូនមកពេទ្យព-១សព្វថ្ងៃហ្នឹង ។

ប៊ុនថនៈ ចឹងព-១នៅមង្គលបូរីនិងស្វាយហ្នឹងនៅជិតគ្នាដែលមីង?

ហ៊ីយៈ ជិតមានអីឆ្ងាយ ឡានជិះតែមួយភ្លេតៗ ។

ប៊ុនថនៈ តែពេទ្យព-១នៅមង្គលបូរីហ្នឹងគេហៅពេទ្យតំបន់ដែរ?

ហ៊ីយៈ អត់ទេ ហ្នឹងខាងតំបន់បី មង្គលបូរីនៅខាងតំបន់បីខាងមីងនិងស្វាយហ្នឹងចែកគ្នាណាស់ ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ ខាងស្វាយចឹងទៅនៅខាងតំបន់៥ចឹងទៅ ខាងនោះខាងតំបន់៣នៅខាងនោះភូមិភាគហើយ ។

ប៊ុនថនៈ ចឹងប្រធានពេទ្យមីង?

ហ៊ីយៈ ប្រធានពេទ្យខ្ញុំស្លាប់អស់ហើយឈ្មោះបងគឿន បងដៃគាត់ស្លាប់អស់ហើយគេយកវៃចោលអស់ហើយ ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ យកវៃចោលនៅក្នុងចំការគហ្នឹងឯង ថានៅតែមានមូលហេតុចឹង ។

ប៊ុនថនៈ ចឹងកាលមីងទៅពេទ្យដំបូងរៀនតែម្តងមីង?

ហ៊ីយៈ រៀនជាក់ស្តែងតែម្តង ។

ប៊ុនថនៈ រៀនអីខ្លះមីង?

ហ៊ីយៈ ពីមុនចូលដីបូងមកដល់គេឲ្យមីងទៅបង្កើតគេ បង្កើតក្មួយអើយខ្លាចណាស់ ខ្លាចកូនងាំណាស់ ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ កាន់ហើយលែងទទួលហើយលែងព្រោះខ្លាចកូនងាំនោះ ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ ដល់ពេលគេសម្លុតឲ្យថាមិត្តឯងធ្វើចឹងធ្វើចឹងមិនចេះទេ មេគេសម្លុតឲ្យណាស់ ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ ព្រោះមីងខ្លាចគេយកទៅវៃចោល ថាមិត្តឯងបាននាំទៅកសាងខំចាប់ទឹកភ្នែកទឹកអីដងហ្នឹងទី១ ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ ទី២បង្កើតនៅទៀតបានទទួលកូនពង ។

ប៊ុនថនៈ កូនពងអត់មានកូនទេ?

ហ៊ីយៈ អត់មានកូនទេក្មួយរីកដូចគ្រាប់ដីចឹង តែដូចជាពងពស់ចឹង ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ តែមានខែ្សពីរខែចាប់ពីបីខែចាប់ផ្ដើមចុកហើយ ដល់ពេលហើយធ្លាក់ឈាម ឲ្យតែចុកធ្លាក់ឈាមរបៀបកូនក្រៅស្បូន ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ ដល់ពេលហើយទៅបានយើងធ្វើទៅបានអ្នកជំងឺហ្នឹងយកបានអស់មកអ្នកជំងឺធូរទៅ ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ តែប៉ុណ្ណឹងទេ បើយើងមិនកើតហ្នឹងវាចុកវាឈឺហើយ បើយើងកើតហើយចឹងវាអត់មានឈឺទៀតទេ ។

ប៊ុនថនៈ ចឹងមីងរៀនតែពេទ្យឆ្មបមីង មីងមានរៀនផ្នែកអីផ្សេងទេ?

ហ៊ីយៈ អត់ទេ ជំនាន់ហ្នឹងបើក្មួយឯងដាំបាយក្មួយឯងដាំតែបាយទេ ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ ក្មួយឯងនៅកន្លែងពេទ្យមែនតែក្មួយឯងជាអ្នកដាំបាយ ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ ក្មួយឯងដាំបាយស្វតែក្មួយឯងមិនចេះពេទ្យទេ ។

ប៊ុនថនៈ តែនៅខាងពេទ្យដែរ?

ហ៊ីយៈ ចាស!តែមីងគេឲ្យនៅខាងជំងឺទូទៅដែរ តែមីងខ្ទើមមីងមិននៅ ។

ប៊ុនថនៈ ខ្ទើមស្អីគេ?

ហ៊ីយៈ ខ្ទើមអ្នកជំងឺនោះ អ្នកជំងឺដូចថាខេះខោះអីមើលទៅប្រឡេះប្រឡុះអីមីងអត់ទេ មីងធ្វើតែឆ្មបហ្នឹង បើមានអ្នកសម្រាលហ្នឹងក៏ទៅៗ មានឆ្ងាយអីសម្រាក់តែជាមួយគ្នាហ្នឹងតែយើងបន្ទប់ផ្សេងគ្នា ។

ប៊ុនថនៈ មានអ្នកជំងឺច្រើនទេមីង?

ហ៊ីយៈ មានច្រើន ។

ប៊ុនថនៈ ភាគច្រើនប្រជាជនធម្មតា?

ហ៊ីយៈ ប្រជាជនធម្មតា ។

ប៊ុនថនៈ មានកង់ទ័ពអីទេ?

ហ៊ីយៈ មានកង់ទ័ពដូចសព្វថ្ងៃហ្នឹង ។

ប៊ុនថនៈ លាយចំរុះគ្នា?

ហ៊ីយៈ លាយចំរុះគ្នាបើយើងមិនធ្វើខ្លាចគេ ។

ប៊ុនថនៈ ចឹងមីងចេះចាក់ថ្នាំអីទេ?

ហ៊ីយៈ ចេះតើ តែមីងអត់ទេរាល់ថ្ងៃ ចេះទាំងអស់មិនមានអត់ទេ សព្វថ្ងៃគេចែងច្បាប់ថាទោះជាយើងចេះសម្រាលប៉ុណ្ណានៅក្នុងភូមិ យើងអត់ត្រូវការសម្រាលទេយើងត្រូវបញ្ជូនទៅមណ្ឌលសុខភាព ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ មានសមត្ថភាពល្អបើយើងសម្រាលមានបញ្ហាមួយសង់ជាបីអាអូនច្បាប់ឥឡូវយើងមានអីសងគេយើងក្រ ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ ចឹងទៅកន្លែងមណ្ឌលសុខភាពហ្នឹងវាល្អជាង មានបញ្ហាអីដោះស្រាយស្រួលមានឧបករណ៍គ្រប់គ្រាន់អត់មានអីនេះទេ ។

ប៊ុនថនៈ និយាយមកទៀតមីង?

ហ៊ីយៈ ដឹងនិយាយថាម៉េចទៀត ។

ប៊ុនថនៈ ចឹងកាលមីងនៅតំបន់៥ បានយូរទេ មានផ្លាស់ប្តូទៅណាទេ?

ហ៊ីយៈ អត់មានផ្លាស់ទេក្មួយ តែទាល់៧៨និរតីចូលមកចាប់វៃចោលបណ្តើរៗ ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ ចាប់វៃចោលកាលជំនាន់ឪខ្ញុំហ្នឹងណាស់ ចាប់វៃចោលៗតែម្ដង ។

ប៊ុនថនៈ និយាយថាខាងនិរតីចូលមកហ្នឹងចាប់តែម្ដង?

ហ៊ីយៈ ខាងយាយថែមនោះ ។

ប៊ុនថនៈ យាយថែម?

ហ៊ីយៈ ចាស! ។

ប៊ុនថនៈ យាយថែមហ្នឹងគាត់ខាងអីវិញមីង?

ហ៊ីយៈ ចៅហ្វាយស្រុក ចឹងតាំងពី៧៥មកមិនកើតចៅហ្វាយស្រុក ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ ក្មួយឯងមិនកើតហើយមីងបន្ទាប់ៗគ្នាចឹងទៅ ដល់ពេលគេចោទថាក្មួយឯងហ្នឹងចេះៗទៅ ខាងនិរតីចុះមកក្ដាប់ម្ដងគេមិនយកក្មួយឯងទៅវៃចោល ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ ហើយអ្នកផ្សេងទៀតហ្នឹងមិនចូលមកកាន់តំណែងខ្លួនឯងវិញ ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ ក្មួយឯងកើតជាខ្មោចបាត់ហើយ មិនឃើញទួលស្វែងហ្នឹងឯងគោកឯងទុល ។

ប៊ុនថនៈ ចឹងនិយាយថាមុនយាយថែមហ្នឹងពីណាជាអ្នកកាន់កាប់?

ហ៊ីយៈ យាយថែមមិនដឹងដែលថាមកពីខាងនិរតីមក ។

ប៊ុនថនៈ បាទ!និយាយមុនគាត់ទៀតមានពីណា?

ហ៊ីយៈ ឈ្មោះ បង ម៉ោង បង ហ៊ុង បង វ៉ាល់ តា ញ៉ឹម ញ៉ឹមហ្នឹងភូមិភាគតែងាប់អស់ហើយ សព្វថ្ងៃកើតជាខ្មោចអស់ហើយ ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ បងជាហ្នឹងគាត់ជាអគ្គការនារីយុវជនណាស់ ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ ហើយបងអេតហ្នឹងក៏ខាងនាទីយុវជនដែរ ខាងនារីណាស់ហើយបង ញ៉ឹមហ្នឹងខាងភូមិភាគ ហើយបង ហ៊ុងហ្នឹងខាងតំបន់ ។

ប៊ុនថនៈ ចឹងមីងមានស្គាល់គាត់ទេ?

ហ៊ីយៈ ស្គាល់តែងាប់អស់ហើយ ។

ប៊ុនថនៈ តែបានជួបគាត់ទេ?

ហ៊ីយៈ អត់ទេ កាលហ្នឹងមីងនៅកន្លែងពេទ្យហ្នឹងប៉ុន្ដែមិនហ៊ានទៅជួបគេអ្នកធំនោះ ។

ប៊ុនថន៖ បាទ ។

ហ៊ឺយ៖ យើងតូចតាចមិនហ៊ានទៅជួបអីសម័យនោះ ។

ប៊ុនថន៖ តែមីងស្គាល់គាត់ដែរ?

ហ៊ឺយ៖ ស្គាល់តែមុខទេ មិនដែលជួបនិយាយសំដីសំដៅអីអត់ទេខ្លាចគេណាស់ ។

ប៊ុនថន៖ ចឹងគាត់មានមកជួបអកធ្វើការអីទេ?

ហ៊ឺយ៖ គាត់មកប្រជុំកន្លែងពេទ្យអីហ្នឹង អីចឹងដែលតើ ពង្រីកពង្រឹងបង្កបង្កើនផលអីចេះចុះ ។

ប៊ុនថន៖ បាទ ។

ហ៊ឺយ៖ គាត់ចូលប្រជុំតែមិនដែលហ៊ានមើលមុខគេ គេអ្នកធំយើងរាស្ត្រសាមាញ្ញ ។

ប៊ុនថន៖ ខស្សាហ៍មកប្រជុំជាងគេពីណាវិញ?

ហ៊ឺយ៖ ប្រជុំមានតែស្រុកហ្នឹងហើយ ។

ប៊ុនថន៖ ស្រុកពីណា?

ហ៊ឺយ៖ ស្រុកតា ម៉ោង ។

ប៊ុនថន៖ ចឹងតា ញឹមអីគាត់ដែលមកទេ?

ហ៊ឺយ៖ តា ញឹមគាត់ជាប្រធានភូមិភាគគាត់ធ្វើម៉េចមក តា ញឹមគាត់តំបន់កាលឆ្នាំ៧៨ហ្នឹងចាប់អស់រលីង ។

ប៊ុនថន៖ ចាប់ពីណាខ្លះ?

ហ៊ឺយ៖ ចាប់មេៗអស់រលីង ។

ប៊ុនថន៖ ចឹងខាងពេទ្យអ្នកមីង?

ហ៊ឺយ៖ ទាំងអស់ ប៉ុន្មានឡានហ្នឹងដាក់យកទៅទាំងអស់ ។

ប៊ុនថន៖ ចឹងពេលចាប់ហ្នឹងមីងនៅពេទ្យហ្នឹងតែម្តង?

ហ៊ឺយ៖ នៅ តែមីងចាប់ក្រោយ មីងចាប់នៅថ្ងៃទី១៥ ខែ៨ឆ្នាំ៧៨ ។

ប៊ុនថន៖ ចឹងប្រធានមីងណាស់?

ហ៊ឺយ៖ ចាប់អស់ហើយគ្មានសល់ទេ ចាប់កាលជំនាន់តា ញឹម ចាប់អស់ឲ្យតែមេៗថាបោសសម្អាតយកម៉ាប្រាស់ក្លួយ ។

ប៊ុនថន៖ ថីបានចាប់មីង?

ហ៊ឺយ៖ មិនដឹង ជាមូលហេតុអីដែរ ។

ប៊ុនថន៖ ចាប់ពីណាមុនគេមីង?

ហ៊ឺយ៖ គេហៅទៅប្រជុំចឹងគេហៅសុទ្ធមេៗចឹងទៅណាស់ មានពិបាកដើរចាប់ណា ។

ប៊ុនថន៖ ប្រជុំនៅណាវិញ?

ហ៊ឺយ៖ ប្រជុំនៅស្វាយហ្នឹង នៅកន្លែងទទួលភ្ញៀវហ្នឹង ។

ប៊ុនថន៖ កន្លែងទទួលភ្ញៀវនៅម្តុំណាវិញ?

ហ៊ឺយ៖ ទទួលភ្ញៀវខាងនេះបេនឡាននោះ ខាងជើងដីងខាងត្បូងផ្លូវចេញមកសៀមរាបនោះ កន្លែងសព្វថ្ងៃមិនដឹងជាគេដាក់ស្អីទេ ។

ប៊ុនថន៖ ខ្ញុំមិនសូវស្គាល់ច្បាស់ដែរ?

ហ៊ឺយ៖ មានលក់សាំង កន្លែងការ៉ាស់សាំងចេញមកសៀមរាបនោះមួយមិនចេះទៅខាងស្តាំដៃហ្នឹង មិនកន្លែងទទួលភ្ញៀវ ។

ប៊ុនថន៖ គេហៅកន្លែងស្អីវិញ?

ហ៊ឺយ៖ មិនដឹង ។

ប៊ុនថន៖ គេហៅជាមន្ទីរឬមួយជាអី?

ហ៊ឺយ៖ គេហៅកន្លែងពាណិជ្ជកម្មតំបន់ កាលហ្នឹងដឹកសម្ភារៈ បើដូចជាអង្ករដូចជាខោអាវដូចជាថ្នាំពេទ្យអីចឹងណាស់ ។

ប៊ុនថន៖ បាទ! ហៅទៅប្រជុំនៅហ្នឹងទាំងអស់?

ហ៊ឺយ៖ ហៅទៅប្រជុំកន្លែងទទួលភ្ញៀវហ្នឹង កន្លែងទទួលភ្ញៀវហ្នឹងមានកន្លែងសម្ងាត់គេមួយផ្ទះថ្ម ខាងនេះនោះ ។

ប៊ុនថន៖ បាទ

ហ៊ឺយ៖ ខ្ញុំស្មានថាគេប្រជុំមែន ចាប់អស់ទៅណាស់ ។

ប៊ុនថន៖ ចឹងមីងដឹងដែលកាលគេចាប់?

ហ៊ឺយ៖ ចុះមីងនៅជិតហ្នឹងមីងមិនដឹង មីងនៅព្យាបាលទៅចាក់ថ្នាំឲ្យគេចឹងទៅ គេហៅទៅចាក់យកថ្នាំអាចម៍ទន្សាយឲ្យគេលេបនោះ ។

ប៊ុនថន៖ បាទ ។

ហ៊ឺយ៖ ថ្នាំយើងសូនៗដែនោះ ទៅយកទៅឲ្យគេលេបនោះ គេប្រើឲ្យយកទៅឲ្យ យកទៅឲ្យគេទៅ ទៅឃើញតែគេចាប់ចងជាន់ស្លាបសេកគេមិនឲ្យនិយាយទេ ។

ប៊ុនថន៖ ចឹងពេលចាប់ហ្នឹងមីងឃើញពីណា?

ហ៊ឺយ៖ ឃើញតើខាងនិរតីមកចាប់ ចាប់អ្នកចាស់យើងដែលជាអ្នកកាន់មូលដ្ឋានយើងនៅដូចជាមេៗមុនៗនោះ ។

ប៊ុនថន៖ មេហ្នឹងពីណាខ្លះមីង?

ហ៊ីយៈ ថាឃើញចាប់រាប់មិនអស់ទេក្មួយ ចុះម៉ាស្រុក ។

ប៊ុនថនៈ មីងស្គាល់ដែរ?

ហ៊ីយៈ ប៉ុន្មានសន្កាត់ហ្នឹង ។

ប៊ុនថនៈ មីងស្គាល់ទេ?

ហ៊ីយៈ ស្គាល់ឥឡូវងាប់អស់ហើយ ។

ប៊ុនថនៈ ចឹងកាលចាប់ប្រធានមីងអីមីងមានឃើញផ្ទាល់ទេ?

ហ៊ីយៈ ចាស! ឃើញបង ខឿនប្រធានពេទ្យអីហ្នឹង ។

ប៊ុនថនៈ ចឹងមីងយកថ្នាំទៅឃើញគេចាប់តែម្ដង?

ហ៊ីយៈ ឃើញតើ ។

ប៊ុនថនៈ តែមានហៅមានអីទេ?

ហ៊ីយៈ អត់ទេ ។

ប៊ុនថនៈ មីងលបមើលឬឈរមើលតែម្ដង?

ហ៊ីយៈ អត់ហ៊ានទេ គ្រាន់តែក្រឡេកឃើញគេចាប់ខ្ញុំដឹងហើយមិនហ៊ានទាំងឈរដងហ្នឹងណាស់ ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ វេទនាគេចាប់យើងដែលទៅមិនងាប់ ។

ប៊ុនថនៈ តែគេមិនថាអីដែរចាប់មីងឃើញ?

ហ៊ីយៈ ធ្វើអីម៉េចបើយើងមិនបានធ្វើធំនិងគេ គេម៉េចចាប់យើង យើងកសាងតែខ្លួនយើងទៅ ដឹនាន់ហ្នឹងមិនដឹងគេប្រជុំថាចន្លុលណាស្អុយកាត់ចន្លុលហ្នឹងទៅ គេមានមកលូកលាន់ដល់យើងណា ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ យើងខំប្រឹងប្រែងតែខ្លួនទៅ ។

ប៊ុនថនៈ មីងចាប់កាលហ្នឹងប្រហែលជាច្រើននាក់ទេមីង?

ហ៊ីយៈ ឡានអាស្រ៊ុបចិនសម័យបីឆ្នាំ ពីរបីឡានដែលហ្នឹងច្រើនដែលហ្នឹងតាំងពីព្រះនេត្រព្រះ ប៉ុន្មានស្រុកនោះ ។

ប៊ុនថនៈ មីងនៅខាងព្រះនេត្រព្រះ?

ហ៊ីយៈ ទេ មីងនៅខាងស្វាយ តែមីងមិនដែលសូវនេះហ្នឹងគេទេ គេថាយើងមិនចេះអក្សរចឹង ឲ្យតែគេប្រើទៅណាទៅ ។

ប៊ុនថនៈ បាទ

ហុឹយៈ បើថាឲ្យយើងចេះអក្សរមិនចេះទេ គេធ្វើម៉េចនេះយើងបើយើងមិនចេះអក្សរចឹង ។

ប៊ុនថនៈ បាទ ។

ហុឹយៈ តែថាជំនាន់គេប្រើខ្លាំងអ្នកល្ងង់ដូចមីងចឹង គេប្រើសាប់ក្រឡាមែន គេថាហក់យកថ្នាំទៅឲ្យអ្នកនេះយកថ្នាំទៅឲ្យអ្នកនោះ ការផ្សារអ៊ីសំខាន់មិនមានទេ ។

ប៊ុនថនៈ ចឹងនៅពេលដែលគេចាប់ប្រធានមីងហើយហ្នឹងមានពីណាឡើងជំនួស?

ហុឹយៈ យី!ចាប់បានតែប៉ុន្មានថ្ងៃហ្នឹង មិនដឹងជាម៉េចគេមកយកនៅមន្ទីរពេទ្យឡើងប៉ុន្មាននាក់ទៀតជាប់ម៉ោងកកោះនេះ ដល់៧៩បានមីងដោះចេញចឹងមិនដឹងជាឡើងពីណាអីណី ។

ប៊ុនថនៈ បាទ ។

ហុឹយៈ មីងគេចាប់ដែរ ។

ប៊ុនថនៈ ចាប់ដែរ?

ហុឹយៈ ចាប់ ចាប់ឡើងប៉ុន្មាននាក់ទៀតនោះ ។

ប៊ុនថនៈ ចឹងចាប់ហ្នឹងចាប់មីងនិងអ្នកផ្សេងទៀតមីង?

ហុឹយៈ ចាប់ ។

ប៊ុនថនៈ ចាប់ប្រធានមីងបានប៉ុន្មានថ្ងៃបានគេមកចាប់មីងទៀត?

ហុឹយៈ ចាប់ទៅបានតែមួយយប់ ។

ប៊ុនថនៈ ចឹងមកចាប់មីងទៀត?

ហុឹយៈ ចាស!អា សារិន វានៅស្វាយខាងសន្តិសុខមកចាប់ដាក់ឡានៗកាលហ្នឹងមិនថាអាធំអាតូចអីទេ វាចេះតែចាប់ទៅៗឲ្យតែពេញគុកទៅមិនដឹង ។

ប៊ុនថនៈ បាទ ។

ហុឹយៈ មីងគេចាប់ដល់ថ្ងៃ៧មករាហ្នឹង មីងគេយកយប់នេះឯងដល់វេនមីងគេយកទៅវៃចោលហើយណាស់ ។

ប៊ុនថនៈ បាទ ។

ហុឹយៈ ព្រោះវាយកពីដើមទីហ្នឹងអស់ហើយ វាអស់ដូចយប់មិញចឹងណាស់ ។

ប៊ុនថនៈ បាទ ។

ហុឹយៈ ដល់នេះត្រូវយកពួកមីងទៅហើយ តែថ្ងៃហ្នឹងចៃដន្យអីខាងហេង សំរិនមក កាលហ្នឹងហេង សំរិន ចុះមកផ្ទាល់ ខ្ញុំស្គាល់ហេង សំរិនច្បាស់ណាស់ កូនក្រមុំគាត់មួយហើយទ័ពខ្មែរទ័ពវៀតណាមអីមកជាមួយដែរ ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ	ហើយស្រែករំពងអឺងអាប់ រណសិរ្សសាមគ្គីសង្គ្រោះជាតិ ចូលកន្លែងគុកហ្នឹងដោះពីគុក យកមកវិញបណ្ដោយហើយស្រីៗវៀតណាមបំប៉នបាយយើង ។

ប៊ុនថន:	ចឹងកាលគេចាប់ហ្នឹងគេចាប់មីងនៅមន្ទីរពេទ្យតែម្ដងឬហៅទៅប្រជុំ?

ហ៊ីយៈ	អត់ទេ មកចាប់នៅកន្លែងនៅ ។

ប៊ុនថន:	ចាប់មីងហើយចាប់ប៉ុន្មាននាក់ទៀត?

ហ៊ីយៈ	ក្មួយអើយកាលហ្នឹងមិនដឹងជាប៉ុន្មានទេ ម៉ាឡានអាស៊ីបច្រើនគ្រាន់ដែរ ។

ប៊ុនថន:	តែខាងពេទ្យទេឬមួយមានខាងណាផ្សេងៗទៀត?

ហ៊ីយៈ	ចាស!ចាប់តែខាងពេទ្យ ។

ប៊ុនថន:	ដាក់មួយឡានទៅ?

ហ៊ីយៈ	ដាក់មួយឡានទៅ មីងជាប់គុកឆ្នាំ៧៨ថ្ងៃទី១៥ ។

ប៊ុនថន:	ខែប៉ុន្មានមីង?

ហ៊ីយៈ	ខែ៨ ឆ្នាំ៧៨ដូចគ្នាហើយចេញពីគុកវិញថ្ងៃទី៧មករា ឆ្នាំ៧៩ ។

ប៊ុនថន:	ចឹងមីងអ្នកដែលមកចាប់ហ្នឹង?

ហ៊ីយៈ	ងាប់អស់ហើយក្មួយអើយរាល់ថ្ងៃហ្នឹង គេវ៉ៃចោលតគ្នា ។

ប៊ុនថន:	ចឹងកាលគេមកចាប់ហ្នឹងមីងខុសអី?

ហ៊ីយៈ	អត់មិនដឹងជាខុសអី គេមិនប្រាប់រឿងមូលហេតុយើងអត់ទេ មិនដឹងមិនដឹងថាខុសអី ។

ប៊ុនថន:	បាទ ។

ហ៊ីយៈ	គេចេះតែយកៗទៅឲ្យតែពេញគុកទៅមិនដឹង ចុះក្មួយឯងគិតអីគិតតែអាងត្រពាំងថ្មយើង នេះ គ្នានៅទើមៗៗធម្មតាហូបបបរនោះយប់ឡើងហៅទៅកសាងធ្វើស្នូរដី ។

ប៊ុនថន:	ម៉េចបានមីងដឹងរឿងដល់ហ្នឹង?

ហ៊ីយៈ	និយាយមិនដឹងណា មិនព្ទមីងប្រាប់ក្មួយឯងថាគេប្រើមីងទេ គេថាយកថ្នាំទៅឲ្យកងចល័ត ជិះកង់ទៅហើយ ជិះកង់ពីស្វាយមកណាស់ក្មួយ ។

ប៊ុនថន:	បាទ ។

ហ៊ីយៈ	ហើយដូចជិតអើយជិត ។

ប៊ុនថន:	ត្រពាំងថ្មទៅពីនេះ?

ហ៊ីយៈ	ពីស្វាយដូចជាមិនឆ្ងាយ ។

ប៊ុនថន:	ជិត៥០គីឡូ?

ហ៊ីយៈ ចាស!ដូចមានថ្ងៃណាមេទៅប្រជុំចិនជិះឡានទៅជាមួយគេ យកថ្នាំមកបើកឲ្យគេចិនទៅណាស់ ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ ទៅវិញក៏ជិះឡានទៅជាមួយគេវិញទៅណាស់ យកថ្នាំមកបើកឲ្យគេចិនទៅណាស់ ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ ដូចក្មួយឯងថ្នាំសហត្រូវសម្ងាប់ប៉ុន្មានស្គាយយកមកឲ្យគេវិញទៅ ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ ហើយយើងទៅវិញទៅ អ្នកអត់ចេះអក្សរគេប្រើផាប់ក្រឡាមីងមិននេះណា ។

ប៊ុនថនៈ បាទ!ចិនមីងមានស្គាល់កន្លែងគេដែរ គេប្រាប់ឬមួយមានអ្នកនាំទៅ?

ហ៊ីយៈ ដែលយកថ្នាំមកឲ្យគេ ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ មីងស្គាល់តើក្មួយ ទៅដល់ស្ពាននោះស្ពានទី១សព្វថ្ងៃនោះ ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ អាងត្រពាំងថ្មនោះ ។

ប៊ុនថនៈ បាទ!ខ្ញុំធ្លាប់ទៅដល់តើ?

ហ៊ីយៈ ចាស!នៅស្ពានទី១កន្លែងពេទ្យហ្នឹង ។

ប៊ុនថនៈ អត់ចុះទៅដល់ទំនប់ហ្នឹងទេ?

ហ៊ីយៈ អត់ចុះទេ កន្លែងពេទ្យគេបាំងអីនៅហ្នឹងទៅណាស់ ធ្វើជំរកព្យាបាលចល័តនៅលើអាងត្រពាំងថ្មហ្នឹងណាស់ ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ អាងត្រពាំងថ្មមិនមានអាត្រាក់អីទេក្មួយ ។

ប៊ុនថនៈ បាទ!លើកដៃ?

ហ៊ីយៈ លើកដៃរហូត ។

ប៊ុនថនៈ តែមីងដែលទៅដល់ទេ កន្លែងការដ្ឋានគេជីកទេ?

ហ៊ីយៈ ទេ មីងមិនដែលហ៊ានទៅទេ ទៅដាក់តែថ្នាំមិនហ៊ានសម្ងំណា តែហ៊ានសម្ងំគេមិនយកយើងវៃចោលបើគេប្រាប់យើងឲ្យទៅដល់វិញល្ងាចនោះ ។

ប៊ុនថនៈ បាទ!ចិនមានអ្នកជំងឺច្រើនតើ?

ហ៊ីយៈ មានអ្នកជំងឺច្រើន មានអីកាលហ្នឹងស៊ីតែកន្ទក ។

ប៊ុនថន៖ គេនិយាយប្រាប់មីងបានមីងដឹង?

ហ៊ីយ៖ ចាស!គេថាអ្នកជំងឺច្រើនណាស់បងអើយ មិនមានថ្នាំអីលេបទេ ។

ប៊ុនថន៖ ពេទ្យនៅហ្នឹងនិយាយប្រាប់?

ហ៊ីយ៖ ពេទ្យនៅហ្នឹងនិយាយប្រាប់ ពេទ្យសហករណ៍ណាស់ ពេទ្យសង្កាត់អីណាស់ ។

ប៊ុនថន៖ បាទ ។

ហ៊ីយ៖ ទៅៗយើងដុំគេទៅពិបាកគេរកថ្នាំរកអីទៅចល័តអីចឹងទៅណាស់ ។

ប៊ុនថន៖ បាទ ។

ហ៊ីយ៖ គេនិយាយទៅក៏ស្តាប់គេបន្តិចទៅមិនហ៊ាននៅទេ ក្មួយអើយខ្លាច ។

ប៊ុនថន៖ ចឹងមីងយកថ្នាំទៅកន្លែងណាខ្លះ?

ហ៊ីយ៖ យកទៅតែអាងត្រពាំងថ្ម ព្រៃមាន់ រហាល ។

ប៊ុនថន៖ រហាល?

ហ៊ីយ៖ រហាលសាលាឆេះហ្នឹង ព្រះនេត្រព្រះអីចឹងទៅស្រេចតែគេប្រើ ។

ប៊ុនថន៖ ទៅដល់ហ្នឹង?

ហ៊ីយ៖ ចាស ។

ប៊ុនថន៖ ជិះកង់មីងកាលហ្នឹង?

ហ៊ីយ៖ មិនជិះកង់ទេ បើមានឡានមកជាមួយគេទៅ បើអត់មានក៏ជិះកង់ទៅ ។

ប៊ុនថន៖ មេៗហ្នឹងមេពេទ្យដែលជិះឡានហ្នឹង?

ហ៊ីយ៖ ចាស!ត្រូវគេទៅនេះទៅនោះបើជួបជាមួយគ្នាចឹងយើងទៅជាមួយគេទៅណាស់ ។

ប៊ុនថន៖ បាទ ។

ហ៊ីយ៖ បើអត់ទេ ក៏អត់ទៅ ។

ប៊ុនថន៖ ជិះកង់ទៅ?

ហ៊ីយ៖ ចាស!គេថាយើងមិនចេះអក្សរ ទុកកំលាំងឲ្យគេប្រើតែប៉ុណ្ណឹងទេ ។

ប៊ុនថន៖ ចឹងគេចាប់មីងពីពេទ្យហ្នឹងគេយកទៅដាក់ឃុំឃាំងនៅណាវិញ?

ហ៊ីយ៖ នៅកកោះមោងបាត់ដំបង ។

ប៊ុនថន៖ គេហៅ?

ហ៊ីយ៖ គេហៅកកោះមោង សព្វថ្ងៃមិនដឹងជារកម៉េចឃើញទេអូនមិនដឹងជានៅត្រង់ណា ។

ប៊ុនថន៖ តែកាលហ្នឹងមានដឹងថានៅស្រុកអីស្រុកមោង?

ហ៊ីយ៖ មិនដឹងជាស្រុកអីទេអាអូន ខ្ញុំមិនបានដឹងដែរ ។

ប៊ុនថន៖ បាទ ។

ហ៊ីយ៖ អត់ដឹងដែលខាងគេខាងនោះ ចាប់យកទៅដល់គេម្នាក់ពីលើទៅគេយកទៅដាក់គុកទៅគេមានកាន់យើងឲ្យចុះណា គេម្នាក់យើងលើឡានឌិបៗហ្នឹងណាស់ ។

ប៊ុនថន៖ អូ ។

ហ៊ីយ៖ ទាំងចំណងហ្នឹងណាស់ ។

ប៊ុនថន៖ គេចងដៃទៅក្រោយ?

ហ៊ីយ៖ គេចងស្វាបសេករួចទៅគេម្នាក់យើងទៅ ។

ប៊ុនថន៖ មីងភ័យទេកាលហ្នឹង?

ហ៊ីយ៖ គ្មានទេ ព្រលឹងចេញស៊ីអាចម៍អស់ហើយ គ្មាននៅទេក្មួយអើយ ។

ប៊ុនថន៖ មានសួរគេថា?

ហ៊ីយ៖ អត់ទេ មិនហ៊ានទេ ម៉ាជំនាន់ហ្នឹងយើងរាល់ថ្ងៃប្រៀបធៀបដ៏មនិងរាល់ថ្ងៃបើយើងខាន់គឺបានប្រហែលសម័យបីឆ្នាំ អត់ចេះទាស់គ្នាទេ ។

ប៊ុនថន៖ បាទ ។

ហ៊ីយ៖ បើយើងកាន់ខ្វាចចិត្តគ្នាប្រហែលបីឆ្នាំ យើងគ្រាន់តែប្រៀបធៀបគ្នាថាយើងខ្វាចនិយាយទៅលើក្មួយឯងខ្វាចវាខុស ។

ប៊ុនថន៖ បាទ ។

ហ៊ីយ៖ ក្មួយឯងនិយាយមកលើមីងខ្វាចវាខុស ។

ប៊ុនថន៖ បាទ ។

ហ៊ីយ៖ ចឹងយើងប្រៀបធៀបគ្នាកាលសម័យបីឆ្នាំមកដល់សម័យនេះបើប៉ុណ្ណឹងយើងសាមគ្គីគ្នាស្អិតរមួតអត់ចេះទាស់គ្នា ។

ប៊ុនថន៖ អត់ចេះទាស់គ្នា?

ហ៊ីយ៖ ចាស!ល្អណាស់ ។

ប៊ុនថន៖ បាទ ។

ហ៊ីយ៖ បើយើងហានិយាយទៅយើងខ្វាច ចឹងយើងអត់និយាយល្អដាង ។

ប៊ុនថន៖ បាទ ។

ហ៊ីយ៖ អាហ្នឹងគ្រាន់តែប្រៀបធៀបទេក្មួយ មិនចង់បានសម័យហ្នឹងមកវិញទេ ។

ប៊ុនថន៖ បាទ ។

ហ៊ីយ៖ បើកាន់ចិត្តសព្វថ្ងៃដូចពីសម័យហ្នឹងល្អមែនទែន ។

ប៊ុនថន: ចឹងចង់មីងស្គាល់សេកដាក់លើឡានមកកោះហ្នឹងមកតែម្ដង?

ហ៊ីយ: ចាស!ដល់ចូលក្នុងទ្រុងបានគេដោះយើង ។

ប៊ុនថន: ភាគច្រើនអ្នកជាប់ហ្នឹងស្រីឬប្រុសមីង?

ហ៊ីយ: ប្រុសស្រីៗចំរុះគ្នារហូតហ្នឹង ។

ប៊ុនថន: ចឹងចំរុះគ្នា?

ហ៊ីយ: ចាស!ចំរុះគ្នារហូត ។

ប៊ុនថន: និយាយថាយកទៅដល់មន្ទីរឃុំឃាំង?

ហ៊ីយ: ចាស!ទៅដល់ចូលកន្លែងគុកគេវែងណាស់ក្មួយ ។

ប៊ុនថន: បាទ ។

ហ៊ីយ: ទៅដល់គេដឹងយើងបញ្ចូលទៅបានគេស្រាយយើង ។

ប៊ុនថន: បាទ ។

ហ៊ីយ: រួចគេដាក់ខ្នោះទៅ គេបញ្ចូលជើងយើងខ្នោះសិនបានដោះយើង ។

ប៊ុនថន: បាទ ។

ហ៊ីយ: ដល់ហើយគេដើរចែកបបរមួយវែកៗ ។

ប៊ុនថន: និយាយថាគេចង់ហើយទៅដល់ហ្នឹងទម្លាក់តែម្ដង?

ហ៊ីយ: ចាស! គេមិនអាណិតអាសូរយើងទេក្មួយអើយ គេមិនមែនថាលើកចេះចុះអីអត់ ។

ប៊ុនថន: មីងអីចូលទៅច្រើនគ្នាដែរ?

ហ៊ីយ: រាប់រយរាប់ពាន់ក្មួយអើយ ។

ប៊ុនថន: ចុះមន្ទីរឃុំឃាំងគេធំដែរ?

ហ៊ីយ: ធំវែង ។

ប៊ុនថន: មានរបងមានអីទេមីង?

ហ៊ីយ: មានរបងគេប៉ុននេះៗគេប្រឈ ។

ប៊ុនថន: គេប្រឈយ៉ាងម៉េចវិញ?

ហ៊ីយ: រនាបគេប្រឈចេះគេបាំងដូចជារនាបឬស្សីគេប្រឈចឹងៗ ។

ប៊ុនថន: ធំទេមីងកន្លែង?

ហ៊ីយ: ធំក្មួយគុកហ្នឹងធំគ្រាន់តែមើលកន្លែងធំទូលាយទេ មីងមានពេលណាដើរព្រោះអីយើងជាប់គុកដែរ ។

ប៊ុនថន: គេធ្វើអំពីថ្មឬធ្វើអំពីឈើ?

ហ៊ឺយៈ ឈើតើ ។

ប៊ុនថនៈ ចឹងអត់មានខ្វាចអ្នកទោសរត់អីទេ?

ហ៊ឺយៈ គេចាក់សោហើយគេយាម ។

ប៊ុនថនៈ តែមានជញ្ជាំងបាំងទេ?

ហ៊ឺយៈ មាន!ជញ្ជាំងគេពីរជាន់នោះ ។

ប៊ុនថនៈ បាទ ។

ហ៊ឺយៈ អាគ្គាហ្នឹងក្រាលទៅពេលអ្នកយាមគុកមេគុកគេដើរខាងក្រៅទៅ មើលទៅឃើញយើងខាងក្នុងចន្លោះប្រហោងៗចេះ ។

ប៊ុនថនៈ កាលហ្នឹងមានធ្វើទារុណកម្មអីដែលមីង?

ហ៊ឺយៈ គេចាប់យកទៅវ៉ៃចោលរាល់តែថ្ងៃ ។

ប៊ុនថនៈ តែមានធ្វើទារុណកម្ម?

ហ៊ឺយៈ វ៉ៃក្នុងគុកហ្នឹង ។

ប៊ុនថនៈ បាទ ។

ហ៊ឺយៈ អត់ទេ គេអត់វ៉ៃយើងក្នុងគុកទេ តែយប់ឡើងគេបញ្ចេញបួនដប់នាក់ចឹងទៅណាស់ ។

ប៊ុនថនៈ បាទ ។

ហ៊ឺយៈ ដូចថាជួរមីងចឹងគេបញ្ចេញជួរមីងអស់មួយជួរចឹងទៅ អស់ជួរក្មួយឯងទៅសាដានមួយជួរទៀតចឹងទៅណាស់ ។

ប៊ុនថនៈ យ៉ាងម៉េចបានមីងដឹង?

ហ៊ឺយៈ ចុះបើមីងជាប់គុកហ្នឹងនោះ ហើយជួរទី១អស់ហើយមីងទី២ នៅតែជួរមីងហ្នឹងឯងអាពីនោះមកអស់ហើយ ថ្ងៃហ្នឹងវាចៃដន្យដូចមីងបានជំរាបក្មួយចឹងថា ហេង សំរិនចូលមករំដោះផុតទៅ ។

ប៊ុនថនៈ បាទ ។

ហ៊ឺយៈ បានជាមីងបានរស់រានកុំអីមីងស្លាប់ដែលហ្នឹង ។

ប៊ុនថនៈ អ្នកចេញហើយហ្នឹងមីងមានឃើញចូលមកវិញទេ?

ហ៊ឺយៈ អត់ទេ ចេញស្ងាត់ៗបាត់រហូត ។

ប៊ុនថនៈ អ្នកគ្រប់គ្រងនៅហ្នឹងពីណាវិញ?

ហ៊ឺយៈ ទេ ក្មួយអើយមិនដែលស្គាល់គេ ។

ប៊ុនថនៈ ទាហានបុកង់ទ័ព?

ហ៊ីយៈ អត់ស្គាល់ទេ ក្មួយកង់ទ័ពហ្នឹងឯងបើនៅកន្លែងគុកហ្នឹងឃើញអ្នកមានកាំភ្លើងហ្នឹងឯងយាម ខ្លាចយើងរត់យើងអី ដល់ថ្ងៃ៧មករាហ្នឹង អាអ្នកយាមគុកវាប់រស់ហើយអាក្រោះវាដាន់ ។

ប៊ុនថន: បាទ ។

ហ៊ីយៈ វាប់ចំអាអ្នកខ្លាំងៗមួយៗអរនោះអរ ។

ប៊ុនថន: ចឹងមីងជាប់នៅហ្នឹងអស់រយៈពេល ហ្នឹង៤-៥-៦ខែមីង?

ហ៊ីយៈ មិនដឹងជាប៉ុន្មានតាំងពី៧/៨ខែ៨ទៅដល់៧/៩ខែមករា ។

ប៊ុនថន: ចឹង៥ ទៅ៦ខែ?

ហ៊ីយៈ ចាស!កាលហ្នឹងបបរបួន១០គ្រាប់មួយចានធំតែក្បាលដូចត្រីអណ្តែង ។

ប៊ុនថន: ចឹងមានគេបញ្ចេញឲ្យមីងទៅក្រៅទៅធ្វើការអីទេ?

ហ៊ីយៈ អត់ទេ គ្មានថ្ងៃចេញទេ មានថ្ងៃចេញបាត់ខ្លួន ។

ប៊ុនថន: ចឹងអ្នកទោសហ្នឹងមានឈឺមានអីទេ?

ហ៊ីយៈ មានអ្នកសម្រាលកូនស៊ីស្មៅសេះមានអ្នកណាទៅសម្រាលឲ្យយើងទេ ។

ប៊ុនថន: សម្រាលកូនធ្វើយ៉ាងម៉េចទៅ?

ហ៊ីយៈ សម្រាលកូនស៊ីស្មៅសេះទៅដឹកទៅ ។

ប៊ុនថន: កូននៅហ្នឹង?

ហ៊ីយៈ កូននៅហ្នឹងកាត់ចិត្តទៅខ្លះចេះលូនវាទៅ សុំច្បាប់ឲ្យលែងជួយគ្នាចឹងទៅណាស់ ។

ប៊ុនថន: គេដោះដែរ?

ហ៊ីយៈ គេដោះខ្លះដើងចេញយើងទៅជួយកាត់សុខអីគ្នាទៅ ពិបាកនិយាយណាស់វេទនាណាស់ក្មួយនិយាយទៅចង់ស្រក់ទឹកភ្នែក ។

ប៊ុនថន: ដល់ពេលមីងអត់មានឈឺអីទេ?

ហ៊ីយៈ មីងមិនទាន់មានប្តីណា ។

ប៊ុនថន: ចឹងហូបអីហូបបបរមីង?

ហ៊ីយៈ ហូបបបរមានអង្ករតែ១០គ្រាប់ទេ សុទ្ធទឹកហើយអង្ករវីកអត់មានកុហក់ទេអង្ករវីកចង់ប៉ុនចង្កឹះ ។

ប៊ុនថន: បាទ ។

ហ៊ីយៈ បើក្មួយឯងកើតទាន់វេទនាហើយ ។

ប៊ុនថន: ចឹងមានគេហៅទៅសួរប្រវត្តិរូបមីងខុសអីដោយសារអីទេ?

ហ៊ីយៈ អត់ទេ គេមិនប្រាប់កំហុសយើងផង គេមិនចេះប្រាប់ទេពួកអស់នេះនោះ ។

ប៊ុនថនៈ មីងនិយាយឆ្នាំ៧៩ថ្ងៃ៧ហ្នឹង និយាយថាកងទ័ពរំដោះមក?

ហ៊ីយៈ ចាស!មករំដោះអ្នកទោស ។

ប៊ុនថនៈ ចឹងអ្នកទោសទាំងអស់ហ្នឹង?

ហ៊ីយៈ ចាស!មកហុលបាយឆាប់ហ្នឹងវៀតណាមថាកុំឲ្យហូបច្រើន ឲ្យហូបញឹកតែកុំឲ្យហូបច្រើន តិចទៀតហូបទៀតគាត់ប្រាប់ដែរ តែយើងវាហេវ ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ មិនដែលបានបាយនោះ ។

ប៊ុនថនៈ ដឹកមកដាក់ព្រះនេត្រព្រះ?

ហ៊ីយៈ ចាស!យកមកដាក់ផ្លូវចូលទៅព្រះនេត្រព្រះ ដាក់កន្លែងជុបសព្វថ្ងៃ ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ ដាក់នៅហ្នឹង កាលហ្នឹងពីដើមដើមចាន់គិរីធំៗណាស់ ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ គេមិនកាប់ទេ នៅក្រោមដើមហ្នឹងវៀតណាមគេដាំបាយឲ្យហូប ម្ហូបគេឆ្ងាញ់ៗណាស់តែ ហូបហុលបាយឆាប់ចឹបួននាក់ទៀត យើងហុលបាននោះ ។

ប៊ុនថនៈ ចឹងនៅជាមួយកងទ័ពអីទៅ?

ហ៊ីយៈ ចាស!នៅជាមួយកងទ័ពវៀតណាមហ្នឹង គាត់ដឹកមកដាក់ហ្នឹងទៅ ។

ប៊ុនថនៈ ចឹងមីងថាប្រកាសអីនោះ?

ហ៊ីយៈ ប្រកាសម៉េច ។

ប៊ុនថនៈ ថាប្រកាសកងទ័ពរំដោះចូលជួយអីនោះ?

ហ៊ីយៈ គេស្រែតាមឡានហ្នឹង កាលហ្នឹងខ្ញុំភ័យខ្លាចគេយកទៅវៃចោលទៀតនោះ ។

ប៊ុនថនៈ កាលនៅក្នុងគុកហ្នឹងមីងហ្នឹង?

ហ៊ីយៈ ចាស!កាលនៅក្នុងគុកហ្នឹង ។

ប៊ុនថនៈ មិនទាន់ចូលមកដល់ទេ?

ហ៊ីយៈ មិនទាន់ចូលមកទេ តែព្រុសម្លេងណាស់ ព្រុតែរថក្រោះទ្រហឹង ។

ប៊ុនថនៈ ចឹងមានព្រុបាញ់គ្នាអីទេ?

ហ៊ីយៈ អត់មានបាញ់ទេ មានបាញ់គ្នាផង ។

ប៊ុនថនៈ ចឹងអ្នកយាមមីងហ្នឹងនោះ?

ហ៊ីយៈ	មិនពុអ្នកឃាមហ្នឹងមិនដឹងខ្លួនដែរ រថក្រោះ កិនបែកអាចម៍ឆាប់អស់ទៅ ។

ប៊ុនថេនៈ	អត់មានបាញ់តគ្នាទេ?

ហ៊ីយៈ	អត់មានទេ បាញ់យ៉ាងម៉េចកង់ទ័ពឡើងកគោកគដីប៉ុណ្ណឹងជាប៉ុន្មានឡានបួនដបម្ភៃសុទ្ធតែកង់ទ័ពមានសន្សឹមណាឈ្នះបួនដបម្ភៃនាក់នោះ ។

ប៊ុនថេនៈ	បាទ ។

ហ៊ីយៈ	មិនរត់ ។

ប៊ុនថេនៈ	ចឹងរត់ចេញទៅមានអ្នកទោសហ្នឹងអត់មានបាញ់សម្លាប់ទេ?

ហ៊ីយៈ	អត់ទេៗ ។

ប៊ុនថេនៈ	ចឹងនៅទាំងអស់?

ហ៊ីយៈ	អ្នកទោសបានមកយើងហ្នឹងបានខាងរំដោះហ្នឹង ។

ប៊ុនថេនៈ	បាទ ។

ហ៊ីយៈ	បើមិនជឿក្អួយឯងសួរគាត់ទៅ គាត់ខាងរំដោះមីង ។

ប៊ុនថេនៈ	មកមីងស្គាល់ដែរ?

ហ៊ីយៈ	ពីណោះស្គាល់តើ កូនគាត់ច្រៀងកាលចេញហ្នឹងណាស់កូនក្រមុំគាត់មួយ ។

ប៊ុនថេនៈ	មានកូនមកដែរ?

ហ៊ីយៈ	កូនក្រមុំមួយច្រៀងពីរោះណាស់ កូនគាត់ឈ្មោះអីណា ភ្លេចអស់ហើយ ។

ប៊ុនថេនៈ	មកជាមួយគាត់ដែលឬយ៉ាងម៉េច?

ហ៊ីយៈ	ចាស!មកក្រោយដល់ពេលហើយគាត់មកក្រោយទៀតណាស់ ភ្លេចអស់ហើយតែនៅចាំមុខហេង សំរិនបាន ។

ប៊ុនថេនៈ	បាទ ។

ហ៊ីយៈ	ចាំមុខគាត់បាន គាត់ថាមិនអីទេ ប្អូនៗបងប្អូនទាំងអស់គ្នាខ្ញុំមកជួយសង្គ្រោះហើយកុំភ័យខ្លាចឆាប់ផុតទុក្ខផុតទោសហើយឈប់ឆាប់ហើយ ។

ប៊ុនថេនៈ	បាទ ។

ហ៊ីយៈ	កាលហ្នឹងអរគុណគាត់អើយអរ ។

ប៊ុនថេនៈ	គាត់មកនៅជាមួយកង់ទ័ពហ្នឹង?

ហ៊ីយៈ	គាត់អត់មានមកនៅទេ ជាឡានគាត់រត់ចុះរត់ឡើង គាត់មកអើតសួរសុខទុក្ខយើងដែរ ។

ប៊ុនថេនៈ	បាទ ។

ហ៊ីយៈ	គាត់មិនចោលទេ គាត់ថាម៉េចហើយកុំព្រួយកុំភ័យគាត់មកណែនាំយើងកុំចូលសង្គមហ្នឹងទៀតនោះណាស់ ។

ប៊ុនថន៖	បាទ ។

ហ៊ីយៈ	ពួកខ្ញុំសំពះលុតចង្កូងមួយៗ ខ្ទះលុតចង្កូងហើយដួសថ្នោលទៅមានកំលាំងណា ។

ប៊ុនថន៖	បាទ ។

ហ៊ីយៈ	គាត់ក៏ជួកលើកចិងទៅមិនអីទេបានហើយ អរគុណអ៊ី អរគុណបងតាមចាស់ក្មេងចិងទៅ ។

ប៊ុនថន៖	បាទ ។

ហ៊ីយៈ	គេអរគុណគាត់រហូត កាលហ្នឹងគាត់ខ្មៅទេ ហើយកាលហ្នឹងវៀតណាមក្មេងខ្មៅដែរ ។

ប៊ុនថន៖	ចឹងមីងមកនៅព្រះនេត្រព្រះហ្នឹងនៅបានប៉ុន្មានខែ?

ហ៊ីយៈ	មកដល់ប្រហែលម៉ាមានសាច់ ម៉ាមានកំលាំងរត់តាមគេទៅទៀតទៅ ។

ប៊ុនថន៖	រត់តាមទៅណា?

ហ៊ីយៈ	រត់តាមទាហានប៉ុល ពតទៅទៀតទៅណាស់ ។

ប៊ុនថន៖	ចុះខាង?

ហ៊ីយៈ	គេមកយកអង្ករ គេមកយកអង្ករយកស្រូវទៅស៊ីប៉ុល ពតនោះ ។

ប៊ុនថន៖	ក្រែងមីងនៅជាមួយកងទ័ព?

ហ៊ីយៈ	នៅតែយើងដើរ នៅពេលយើងមានកំលាំងយើងមិនដើរ ដើរទៅមិនជួបគេមករកស្រូវមកបែនស្រូវអី ។

ប៊ុនថន៖	បាទ ។

ហ៊ីយៈ	ចុះកងទ័ពយើងមិនឈ្នះតែយាមគ្រប់កន្លែងណា នៅព្រៃមាន់នោះដើមពោធិបីដើមនោះ ។

ប៊ុនថន៖	មីងដើរចេញ?

ហ៊ីយៈ	ដើរចេញនាំគ្នាដើរលេងរកត្រីរកអីទៅជួបទៅគេនាំទៅទៀតមក មកណាស់ រត់មកទៀតទៅណាស់ ។

ប៊ុនថន៖	បាទ!ជួបជាមួយកងទ័ព?

ហ៊ីយៈ	កងទ័ពខ្មែរក្រហម ។

ប៊ុនថន៖	តែគេមានសម្ពុតមីងទេ?

ហ៊ីយៈ	អត់ទេ ។

ប៊ុនថន៖	គេបបួលមីងប្លុយ៉ាងម៉េច?

ហ៊ីយៈ អ្នកដែលស្គាល់យើងនៅជាមួយគ្នាពីដើមណាស់ ដល់ហើយងើងរស់តើ មីរបុលយក់ទៅ ជាមួយខ្ញុំទៀតអីមក ទៅក៏ទៅចុះចេះណាស់ ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ និស្ស័យវានៅតែកម្ម ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ បានវាចឹងនោះ ។

ប៊ុនថនៈ ចឹងមកប៉ុន្មាននាក់មីង?

ហ៊ីយៈ មកបួនប្រាំនាក់ដែរ ។

ប៊ុនថនៈ អ្នកជាប់គុកជាមួយមីងហ្នឹង?

ហ៊ីយៈ ចាស ។

ប៊ុនថនៈ មកជាមួយគេទៀត?

ហ៊ីយៈ មកទៅបានមកដល់សព្វថ្ងៃចឹងទៅណាស់ មានដែលឃើញម៉ែឪទេ ថាមកៗរហូតចឹងមក បែកពីម៉ែឪទៅមករហូត ។

ប៊ុនថនៈ យ៉ាងម៉េចបានជាមីងចង់មកមីង?

ហ៊ីយៈ មិនដឹងក្តួយ មិនដឹងជាយ៉ាងម៉េច មិនជាអារម្មណ៍យ៉ាងម៉េច ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ ឈឺចាប់ថាឈប់មកហើយ តែមិនដឹងជាអារម្មណ៍ទាញយ៉ាងម៉េចបានជាមកទៀត ។

ប៊ុនថនៈ ចឹងចេញពីហ្នឹងមកនៅជាមួយពីណាវិញ?

ហ៊ីយៈ នៅម៉ាដួរដងវែកហ្នឹង ។

ប៊ុនថនៈ ភ្នំដងវែក?

ហ៊ីយៈ ចាស! ចេញពីភ្នំកូនខ្វែងចឹងទៅ ទៅដុបត្រាង ចេញពីដុបត្រាងទៅអណ្តែងមុត ចេញពី អណ្តែងមុតទៅ៨០៨ចេញពី៨០៨ទៅនៅស្រែព្រៃអូបង្គោលយើងហ្នឹង ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ ទៅខាងជាំ ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ អន្លង់វែងហ្នឹង ។

ប៊ុនថនៈ ដំបូងមីងនៅណាវិញ?

ហ៊ីយៈ ដំបូងរត់ទៅ ។

ប៊ុនថនៈ	បាទ!រត់ទៅ?

ហ៊ីយៈ	រត់ទៅនៅជុបត្រាំងនៅគួរនោះពងទឹកនោះ ។

ប៊ុនថនៈ	ស្រុកអីវិញ?

ហ៊ីយៈ	មិនដឹងជាស្រុកអីទេ អាអូន ។

ប៊ុនថនៈ	តែខេត្តអីវិញមីងមានចាំទេ?

ហ៊ីយៈ	ខេត្តបន្ទាយមានជ័យទេដឹង ។

ប៊ុនថនៈ	ខេត្តបន្ទាយមានជ័យ?

ហ៊ីយៈ	ឧត្តរមានជ័យដឹង ។

ប៊ុនថនៈ	ឧត្តរមានជ័យ?

ហ៊ីយៈ	អាចចឹងដឹង ។

ប៊ុនថនៈ	បាទ!នៅហ្នឹងយូរដែលមីង ។

ហ៊ីយៈ	នៅបានប្រហែលជាមួយអាទិត្យ វៀតណាមឡើងវ៉ៃរត់ទៀត ។

ប៊ុនថនៈ	តែនៅម៉ាជួរភ្នំដងរែកមីង?

ហ៊ីយៈ	ចាស!តាមខ្សែក្រវ៉ាត់ ។

ប៊ុនថនៈ	ចឹងមីងមានចូលធ្វើកងទេកាលហ្នឹង?

ហ៊ីយៈ	បើមិនចូលម៉េចទៅហើយដឹកជញ្ជូនចង់ងាប់ ជញ្ជូនគ្រាប់ឲ្យទ័ពវ៉ៃចង់ងាប់ ។

ប៊ុនថនៈ	ចឹងតាំងពីចេញពីហ្នឹងមីងចូលកង?

ហ៊ីយៈ	ចាស!កងទៀតដឹកជញ្ជូន ។

ប៊ុនថនៈ	កាលហ្នឹងគេហៅកងអីមីង?

ហ៊ីយៈ	កាលហ្នឹងទូលអាកាអីទៅណាស់ ។

ប៊ុនថនៈ	តែមីងចេះបាញ់ទេ?

ហ៊ីយៈ	អត់ទេ ចេះដូចតែគ្នាបាញ់ចេះតើ ។

ប៊ុនថនៈ	ចេញពីហ្នឹងចូលកងតែម្តង?

ហ៊ីយៈ	ចាស ។

ប៊ុនថនៈ	គេហៅកងអីវិញមីង?

ហ៊ីយៈ	គេហៅកងដឹកជញ្ជូន ។

ប៊ុនថនៈ	ចឹងឆ្នាំណាបានមីងមកនេះតែម្តង មកម៉ាខ្សែ?

ហ៊ីយៈ	ឆ្នាំណាទេ មិនជាឆ្នាំណាទេវាមិនបានចងចាំវាភ្លេចហើយ ។

ប៊ុនថន៖ បាទ!ចឹងរត់ពីនោះបានប៉ុន្មានឆ្នាំបានមកដល់ម៉ាឡៃនេះមីង?

ហ៊ីយ៖ មិនបានឆ្នាំទេក្មួយ ។

ប៊ុនថន៖ ប៉ុន្មានខែ?

ហ៊ីយ៖ រត់តែមួយភ្លេចហ្នឹង ជិះឡានថៃនោះ ឡានគេដឹកគ្រាប់ពីស្រុកថៃទៅនោះ ។

ប៊ុនថន៖ ចឹងមីងចូលដីថៃ?

ហ៊ីយ៖ ដឹកមកកាត់ដីថៃហ្នឹងហើយក្មួយ កាលហ្នឹងមានផ្លូវណា ផ្លូវឡានមានកាត់ដីថៃហ្នឹងហើយ ។

ប៊ុនថន៖ បាទ ។

ហ៊ីយ៖ កាត់ដីថៃយើងចង់ចុះយើងប្រាប់គេទៅ ។

ប៊ុនថន៖ មានស្នាក់នៅថៃអីទេមីង?

ហ៊ីយ៖ មានស្នាក់ទេ ឡានគេមិនឲ្យយើងបង្អង់ទេ ឡានគេដាក់ខ្ទប់ប៉េះគេមិនឲ្យយើងឃើញទេ ។

ប៊ុនថន៖ ចេញពីហ្នឹងមក មកនៅម៉ាឡៃហ្នឹងតែម្តងមីង?

ហ៊ីយ៖ ចាស!៧៩ហ្នឹងឯង ។

ប៊ុនថន៖ កាលនៅដំបូងមីងនៅណា នៅម៉ាឡៃនេះនៅម្តុំណា?

ហ៊ីយ៖ កាលមកដំបូងនៅផ្សារនោះ ។

ប៊ុនថន៖ នៅផ្សារ?

ហ៊ីយ៖ ចាស ។

ប៊ុនថន៖ ផ្សារហ្នឹងនៅភូមិអីវិញ?

ហ៊ីយ៖ ផ្សារហ្នឹងសុទ្ធតែព្រៃ ព្រៃអាចម៍ ។

ប៊ុនថន៖ បាទ ។

ហ៊ីយ៖ កាប៉េតកាប៉ូតតែនាំគ្នាដាក់លក់កន្លែងកាប៉ូតអាចម៍ហ្នឹង ។

ប៊ុនថន៖ បាទ ។

ហ៊ីយ៖ ទៅត្រង់នេះក៏ព្រៃតែមិនមែនព្រៃធំទេក្មួយ ព្រៃដើមឈើតូចៗហ្នឹងតែវាមានម្ញប់ណាស់ ។

ប៊ុនថន៖ បាទ ។

ហ៊ីយ៖ ទៅនេះក៏ព្រៃទៅនោះក៏ខ្មោចទៅនេះក៏ខ្មោច នៅក្រោយផ្សារសុទ្ធតែខ្មោចហ្នឹងពីមុននោះ ។

ប៊ុនថន៖ អឺ ។

ហ៊ីយ៖ ចាស!ផ្សារយើងហ្នឹង ។

ប៊ុនថន៖ ខ្មោចហ្នឹងខ្មោច?

ហុឹយៈ ខ្មោចទ័ពយើងហ្នឹង ចុចមិនចុចអីផាប់ហ្នឹងណាស់ ហើយខ្មោចត្រូវគ្រាប់ត្រូវអីរបួសបុក៏កើតជំងឺរោគគាខ្លួនឯងខ្លះទៅ ។

ប៊ុនថនៈ បាទ ។

ហុឹយៈ ឈឺតាមនេះខ្លះទៅ នៅខាងក្រោយផ្សារសុទ្ធខ្មោចទេ ឥឡូវកើតផ្ទះអស់រលីង ។

ប៊ុនថនៈ បាទ! ឃើញផ្ទះថ្មុ?

ហុឹយៈ ចាស! ពីដើមសុទ្ធតែខ្មោចហើយព្រៃណាស់អាអូន ។

ប៊ុនថនៈ បាទ ។

ហុឹយៈ ព្រៃហើយខ្មោចហ្នឹងខែវស្សាហ្នឹងទឹក នេះទេសុទ្ធព្រៃម្លប់ឬស្សីហើយព្រៃ.... ។

ប៊ុនថនៈ មីងមកដល់ដំបូងមានមនុស្សមករស់នៅហ្នឹងមុនហើយនៅមីង?

ហុឹយៈ មានតើ មាន ។

ប៊ុនថនៈ ចឹងមីងមកក្រោយដែរ?

ហុឹយៈ ក្រោយតែយើងមកតាមរយៈតស៊ូដូចគ្នា ។

ប៊ុនថនៈ និយាយមកដល់ដំបូងនៅជុំវិញម៉ាខ្សែនេះមានព្រៃមានអីច្រើនទេមីង?

ហុឹយៈ ព្រៃក្លួយអើយតាមនេះមានដង្កែន ឈ្លុស ខ្លា តាមនេះ ។

ប៊ុនថនៈ មានដែលមីង?

ហុឹយៈ មានតើហើយព្រៃណាស់ ហើយតាមហ្នឹងសុទ្ធមីន សុទ្ធតែខ្សែមីនហើយនេះ ។

ប៊ុនថនៈ ម៉ាជួរព្រំដែនហ្នឹង?

ហុឹយៈ ចាស! នេះបន្ទាយយួននៅខាងលើភ្នំនេះ បន្ទាយវៀងណាមណាស់នៅលើភ្នំនេះ ភ្នំនេះមិនមានរូង រូងវៀតណាមតែឥឡូវគេលប់អស់ហើយ ។

ប៊ុនថនៈ ចឹងសុទ្ធព្រៃទាំងអស់ស្នាក់នៅយ៉ាងម៉េចទៅមីង?

ហុឹយៈ បេះតែចំរះចឹងទៅរស់នៅម៉ាបនៗចឹងទៅណាស់ "មួយកន្លែងៗចឹងទៅ" ។

ប៊ុនថនៈ បាទ ។

ហុឹយៈ មានពិបាកអីធ្វើកៅស៊ូធ្វើខ្ទមអីនៅចឹងទៅណាស់ ។

ប៊ុនថនៈ មានប្រជាជនទេមីង កាលមកដល់ដំបូង?

ហុឹយៈ មាន មានច្រើនណាស់ក្លួយ ប្រជាជនៗមួយកងពលមានបេះតិចណានៅព្រោងព្រាតតើ តែកាលហ្នឹងមិនទាន់មានពីណាលូកឡុំពីក្នុងពីអីមកទេ ។

ប៊ុនថនៈ បាទ ។

ហុឹយៈ សុទ្ធអ្នកចាស់ៗនៅនេះទេ សុទ្ធអកចាស់ៗនៅនេះទេ ។

ប៊ុនថន៖ សុទ្ធតែកង់ទ័ពឬមានលាយជាមួយប្រជាជន?

ហ៊ឺយ៖ ចាស!សុទ្ធតែកងទ័ព ។

ប៊ុនថន៖ ប្រជាជនហ្នឹងកងទ័ពហ្នឹងមីង?

ហ៊ឺយ៖ ចាស!ប្រជាជនសុទ្ធតែកងទ័ពឪពុកម្ដាយកងទ័ពដែលរត់មកជាមួយគ្នាចឹងទៅណាស់ ។

ប៊ុនថន៖ បាទ ។

ហ៊ឺយ៖ ក្រោយមកទៀត៩២-៩៤-៩៥បានមានអ្នកក្នុងមក តាមការប្រម៉ានមើលប្រហែលជាមានបញ្ហាខាងក្នុងឬមានទំនាស់គ្នាអីរត់ចូលមកនេះមក ។

ប៊ុនថន៖ បាទ ។

ហ៊ឺយ៖ កន្ទងមកណាស់ ឃើញចឹងច្រើន កន្ទងមកហ្នឹងចូលឆ្នាំ២០០០ហ្នឹងបានច្រើនមែនទែន ។

ប៊ុនថន៖ បាទ ។

ហ៊ឺយ៖ ដូចថាយើងធ្វើប្រវត្តិរូបយើងធ្វើអីទៅ ដូចពួកនេះនិយាយមិញហ្នឹងពូមិញហ្នឹងដើរធ្វើប្រវត្តិរូបអីចឹងទៅគេស្រាវជ្រាវទៅ គេសុំភូមិចឹងទៅគេឃើញឈ្មោះក្ដួយឯងមានបញ្ហា នៅក្នុងភូមិនោះ គេបើកសៀវភៅមកគេឃើញឈ្មោះចឹងទៅណាស់ ។

ប៊ុនថន៖ និយាយថា កាលមកដំបូងហ្នឹងគេមានហៅម៉ាឡៃអីចឹងនៅ?

ហ៊ឺយ៖ គេហៅម៉ាឡៃតែរហូត ។

ប៊ុនថន៖ តែកើតភូមិកើតអីនៅមីង កាលនោះ?

ហ៊ឺយ៖ កាលនោះមិនទាន់កើតទេ ។

ប៊ុនថន៖ ដូចមានភូមិដូង ភូមិវាលហាត់អីនៅ?

ហ៊ឺយ៖ កាលនោះមានភូមិវាលហាត់ហ្នឹងមានតែមុខទេក្ដួយ ។

ប៊ុនថន៖ បាទ ។

ហ៊ឺយ៖ វាលហាត់មានតែមុខហើយភូមិដូងហ្នឹងមានកណ្ដាល ដល់ស្ពានហ្នឹងមានចុងមាត់អូរនោះ ភូមិដំបូកមាននៅនោះ គ្រសេកជ្រុំមាននៅនេះ មានតែតិចៗទេ វាអត់មានទូលាយដូចសព្វថ្ងៃទេ ។

ប៊ុនថន៖ បាទ!តែមានឈ្មោះហើយ?

ហ៊ឺយ៖ មានឈ្មោះហើយ មានឈ្មោះតាំងពីដើមមកហើយ គេដាក់ឈ្មោះឲ្យស្រេច ។

ប៊ុនថន៖ បាទ ។

ហ៊ឺយ៖ កាលនោះសិទ្ធមនុស្សគេចុះមកមានចៅហ្វាយស្រុកគាត់ហៅឈ្មោះភូមិនេះហៅឈ្មោះភូមិនោះចឹងទៅណាស់ ។

ប៊ុនថន៖ បាទ ។

ហ៊ីយ៖ កាលហ្នឹងទេព យុនណាល់នោះគាត់ដាក់ឈ្មោះនេះដាក់ឈ្មោះនេះស្រេច ។

ប៊ុនថន៖ បាទ ។

ហ៊ីយ៖ រៀបរយស្រេចចៅហ្វាយស្រុកមុននោះ មានអីគាត់មានពិបាកអីប៉ុន្មានគាត់ឈ្មោះឲ្យស្រេចតែប្រជាជនអត់ទាន់ទូលាយដូចសព្វថ្ងៃទេ ។

ប៊ុនថន៖ បាទ ។

ហ៊ីយ៖ សព្វថ្ងៃដែលមានកូនមានចៅធំទូលំទូលាយទៅវាចេះតែរៀបការគេទៅចេះតែច្រើនហើយណាមួយអ្នកក្នុងបុកមកនេះច្រើនដែរ ។

ប៊ុនថន៖ បាទ ។

ហ៊ីយ៖ ចាស! ច្រើន ។

ប៊ុនថន៖ ចឹងមីងមកហ្នឹងនៅកន្លែងផ្សារម៉ាឡៃហ្នឹងវហូតឬមួយមានផ្លាស់ទៅណាទៀត?

ហ៊ីយ៖ អត់មានផ្លាស់ទេ ទាស់កន្លែងហ្នឹងចេះក្លួយ កុំអីមីងក៏មិនបានមកនៅកន្លែងនេះដែរ នៅផ្សារហ្នឹងមីងទិញដី ទិញក្រោយគេ ។

ប៊ុនថន៖ បាទ ។

ហ៊ីយ៖ ទិញទៅមានអ្នកខ្លះយកមួយកង់មុខ ខ្លះយកមួយកង់ក្រោយ ហើយសម្រាប់មីងអ្នកអត់មានលុយ ។

ប៊ុនថន៖ បាទ ។

ហ៊ីយ៖ សម្រាប់អ្នកទិញមុខអ្នកមានលុយ ដល់គេបើកបេនសាំងឆ្នាំ២០០៤-២០០៥ហ្នឹងគេចាប់ផ្តើមលក់សាំងអីហ្នឹងក្លួយ ។

ប៊ុនថន៖ បាទ ។

ហ៊ីយ៖ ដល់ទៅគេចាប់ផ្តើមបើកបេនសាំងគេចាប់ផ្តើមគេបិតយើងពីក្រោយចេះមក អត់មានផ្លូវចេញ ។

ប៊ុនថន៖ បាទ ។

ហ៊ីយ៖ កាលហ្នឹងយើងមិនទាន់អភិវឌ្ឍន៍មិនទាន់មានផ្លូវមុខផ្លូវក្រោយទេ មានតែផ្លូវមុខមួយទេ ។

ប៊ុនថន៖ បាទ ។

ហ៊ីយ៖ ចឹងយើងអត់មានផ្លូវចេញយើងមិនលក់ដីហ្នឹងចេញយើងមកទិញនេះ ។

ប៊ុនថន៖ បាទ ។

ហ៊ីយៈ ចឹងបានជាមីងខ្លាតមកដល់នេះ កុំអីក៏មិនបានមកដែលដល់សព្វថ្ងៃគេជឿនលឿនទៅ កសាងលឿនទៅមានផ្លូវក្រោយមួយទៀត វាសោកស្ដាយដីហ្នឹងវាជិតផ្សារទៀត ។

ប៊ុនថនៈ ចឹងពេលមីងមកពីថៃមកនៅម៉ាឡៃដំបូងឆ្នាំណា៧៩ឬ៨០មីង?

ហ៊ីយៈ ចុង៧៩ហើយ ។

ប៊ុនថនៈ ចឹងមីងនៅ៧៩រហូតមានផ្លាស់ទៅណាទៀតមីង?

ហ៊ីយៈ អត់មានទេ នៅហ្នឹងរហូតតែហ្នឹងឯងអត់មានទៅណាទេ ។

ប៊ុនថនៈ ចឹងអត់មានរត់ទៅផ្សេងទៀតទេ?

ហ៊ីយៈ អត់ទេ អត់មានលំបាករត់លូនអីទៀត គ្រាន់តែមុនដំបូង៧៩ហ្នឹងបន្ទាយយើងនៅនេះ យើងនៅភ្នំខៀវនោះ យើងនោះណាស់ ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ តែដល់មកនេះទៅវៀតណាមយើងវ៉ៃព្រំដែនបាក់ទៅ យើងមិនជាន់ដីនេះនៅ យើងវ៉ៃ បោសព្រំដែនវិញនោះ ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ ប៉ុល ពតមិនវ៉ៃបោសព្រំដែនបាន មកជាន់នៅដីនេះ ។

ប៊ុនថនៈ ចឹងមីងមានរត់ទៅណាទៀតទេ?

ហ៊ីយៈ អត់ទេ ។

ប៊ុនថនៈ តែកាលហ្នឹងមានវ៉ៃគ្នាទេ?

ហ៊ីយៈ មាន កាលហ្នឹងមានវ៉ៃមុននោះម៉ាក់ហ៊ីននោះខ្លាំងណាស់នោះ អូសំព័រនោះ ។

ប៊ុនថនៈ ចឹងនៅម៉ាឡៃនេះអត់មានវ៉ៃទេ?

ហ៊ីយៈ អត់ទេ ។

ប៊ុនថនៈ ចឹងមីងនៅរហូតតាំងពី៨១ដល់៨៥-៨៦ហ្នឹងនៅហ្នឹងរហូត?

ហ៊ីយៈ នៅរហូត ។

ប៊ុនថនៈ មានអ្នក?

ហ៊ីយៈ មានអ្នកកាលនោះត្រូវគ្នាជាមួយទាហានខ្មែរខាងក្នុងនោះ ។

ប៊ុនថនៈ ចឹងឮថាអ្នកខ្លះគាត់រត់ទៅជំរំ៨៥អីនោះមីង?

ហ៊ីយៈ មានអ្នកខ្លះរត់ទៅថៃរត់ទៅអាមេរិចអីនោះទៅណាណីទៅណាស់ ។

ប៊ុនថនៈ តែមីងអត់មានរត់ទេ?

ហ៊ីយៈ អត់មានចិត្តរត់ទៅណាទៅណីទេ ។

ប៊ុនថន: អត់មានរត់ទៅនៅជំរំទេ នៅហ្នឹងរហូត?

ហ៊ឺយ: អត់ទេ ខ្លាចគេយកវៃចោលទៀតនោះ ចុះយើងធ្លាប់ជាប់គុកហើយនោះ ។

ប៊ុនថន: បាទ ។

ហ៊ឺយ: ខ្លាចតែងរាប់ប៉ុណ្ណឹងឯង ។

ប៊ុនថន: ចឹងកាលរត់ទៅហ្នឹងមានអ្នកនៅម៉ាឡៃដែរ?

ហ៊ឺយ: មាន មានមិនខ្វះទេអ្នកចង់នោះ ។

ប៊ុនថន: មីងមានចូលកងជីកជញ្ជូនទេ កាលហ្នឹង?

ហ៊ឺយ: ចូលជីកជញ្ជូនចូលអីនោះ ។

ប៊ុនថន: ចូលនៅណាវិញ?

ហ៊ឺយ: ចូលកន្ទែងតា ម៉ុកនោះ ។

ប៊ុនថន: តា ម៉ុកនៅភ្នំដងរែកនោះ?

ហ៊ឺយ: ចាស! តែដល់ពេលឡានគេជីកជញ្ជូនយកគ្រាប់ទៅកន្ទែងតា ម៉ុកហ្នឹងគេមិនមកផ្លូវហ្នឹងវិញ ។

ប៊ុនថន: បាទ ។

ហ៊ឺយ: យើងមកជាមួយឡានគេមក មកមួយយប់ដល់ហ្នឹង ពីដងរែកមកនេះ ។

ប៊ុនថន: បាទ ។

ហ៊ឺយ: ពីស៊ីសាកេតកាលនេះ ជិះពីស៊ីសាកេតមកមានពិបាកអីលឿនតើឡានផ្លូវថៃហ្នឹង ។

ប៊ុនថន: ចឹងកាលមីងចូលមកនៅជិតផ្សារហ្នឹងមីងឈប់ចូលមកកងជីកជញ្ជូន?

ហ៊ឺយ: ឈប់ហើយឆ្នាំ៨០ បានមីងរៀបការជាមួយឪវានេះ រៀបការទៅឈប់ដើរទៅណាហើយ ។

ប៊ុនថន: នៅហ្នឹងរហូត?

ហ៊ឺយ: ចាស ។

ប៊ុនថន: ចឹងពូ?

ហ៊ឺយ: ពូទៅមុខទៅវៃគ្នាចឹងឯង ។

ប៊ុនថន: ការហ្នឹងគ្នាច្រើន?

ហ៊ឺយ: ការហ្នឹងចាប់ដៃគ្នាហ្នឹងណាស់ ការធម្មតាហ្នឹងណាស់ ។

ប៊ុនថន: ការច្រើនគូរទេ?

ហ៊ីយៈ អត់មានច្រើនទេ តែថាមួយគូរក្ដីពីរគូរក្ដីយើងការធម្មតាហ្នឹងណាស់ និយាយឲ្យពរឲ្យជ័យមួយម៉ាត់ពីរម៉ាត់ហ្នឹងណាស់បានជាប្ដីប្រពន្ធបាត់ហើយ ។

ប៊ុនថនៈ តែមានស្គាល់គ្នាពីមុនមកទេ?

ហ៊ីយៈ អត់ទេ គេរៀបឲ្យតែម្ដងជំនាន់ហ្នឹងមាននេះណានៅកុម្មុយនីស្ដនៅឡើយមានពិបាកត្រង់ថាមានពិបាកអី ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ យ៉ាប់ណាស់ក្មួយអើយក្នុងមួយឆាកជីវិតហ្នឹងមីងចាំវេទនាណាស់ ។

ប៊ុនថនៈ តែមុនរៀបការហ្នឹងមានស្គាល់គ្នាដែរ?

ហ៊ីយៈ ស្គាល់ ឃើញមុខគ្នាចឹងតែដឹងគេស្រឡាញ់ដឹងនាក់ណាអ្នកណាស្គាល់ៗ តែយើងមិននិយាយថា មីងអើយត្រង់នេះពូអើយត្រង់នោះមិនដែលទេ យើងមិនដែលនិយាយរកគ្នាទេ ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ តែគេមើលយើងឃើញចំណាស់ៗដែរ គេរៀបការឲ្យទៅណាស់ ។

ប៊ុនថនៈ តែមីងពេញចិត្តដែលកាលហ្នឹង?

ហ៊ីយៈ ទេ មិនពេញដែលហ្នឹង តែដូចជារាល់ថ្ងៃកូនមួយកូនពីរទៅវាធម្មតាវិញហើយណាស់ ។

ប៊ុនថនៈ មិនពេញចិត្តយ៉ាងម៉េចមីង គាត់អត់ស្អាតឬមួយយ៉ាងម៉េច?

ហ៊ីយៈ មិនពេញចិត្តព្រោះមិនទាន់ចង់បានប្ដី ។

ប៊ុនថនៈ ចឹងរៀបការហ្នឹងមានអ្នកណាអត់ស្រឡាញ់សុំមិនរៀបការមានទេ?

ហ៊ីយៈ មានតើ គេខ្វាចមួយមុខហ្នឹង ខ្លាចតែវាអស់ជីវិតណាស់ ។

ប៊ុនថនៈ ចឹងរបកែកអត់មានបន្ទោសអីទេ មីង?

ហ៊ីយៈ អត់ទេ ខ្លះរៀបការហើយមិនដេកនៅជាមួយគ្នាក៏បាន យើងមានពេញសិទ្ធទៅយើងរត់ចេញទៅណាស់ យើងលែងលះគ្នាក៏បាន ខ្លះនៅជាប់គ្នាដូចមីងរាល់ថ្ងៃចឹងក៏មាន ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ នៅរក្សាគ្នារៀងរហូតក៏មាន ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ ដួនអីអាក្រក់តែរូបមែនចិត្តគេបានក៏មាន ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ យើងទៅរកអ្នកស្អាតម៉ោកមាំងទៅយ៉ាងម៉េចទៅ ។

ប៊ុនថន: ចឹងមីងការហើយនៅហ្នឹងទៅរបបហូបចុកយ៉ាងម៉េចដែរមីង?

ហ៊ីយៈ មានអីធម្មតាក្មួយ បើកអង្ករអីធម្មតាអត់មានអត់ឃ្លានទេ។

ប៊ុនថន: ចឹងមីងហូបតែរបបបើកហ្នឹងមានរកអីផ្សេងទៀតទេ?

ហ៊ីយៈ អត់មានរកទេ ហូបតែរបបបើកអង្ករមួយអាទិត្យអង្ករមួយប៉ោតហូបម៉េចអស់ម្នាក់ឯង។

ប៊ុនថន: ចឹងមីងនៅតែផ្ទះចឹងទៅអត់មានធ្វើ?

ហ៊ីយៈ ចាស!អត់មានធ្វើអីទេ យើងមានប្ដីហើយមានទៅណា គេអត់មានហៅអត់មានរកទេ។

ប៊ុនថន: បាទ។

ហ៊ីយៈ គេកើតមីង។ហើយបើយើងនៅលីវបានហៅរកវាស្រួលចឹងម្យ៉ាងម្នាក់ដែលក្មួយ។

ប៊ុនថន: កាលហ្នឹង៨០ប៉ុន្មាន?

ហ៊ីយៈ កាលហ្នឹង៨១-៨២។

ប៊ុនថន: មីងការហើយ?

ហ៊ីយៈ ៨០មីងការហើយ មានគ្រួសារហើយ។

ប៊ុនថន: មីងនៅរហូតដល់?

ហ៊ីយៈ ដល់ឆ្នាំ៨២មីងមានកូនមួយហើយ កូនមួយតែស្លាប់កើតមកកូនស្លាប់។

ប៊ុនថន: ចឹងរហូតដល់៩០ជាងបោះឆ្នោតហ្នឹងមីងនៅ?

ហ៊ីយៈ ៩៨ក្មួយ។

ប៊ុនថន: ៩៣?

ហ៊ីយៈ ៩៣។

ប៊ុនថន: ៩៣បោះឆ្នោតដំបូង?

ហ៊ីយៈ ៩៣បោះឆ្នោតនៅកន្លែងនេះកន្លែងបេនសាំងសព្វថ្ងៃនេះ បេនសាំងផ្លូវចូលមកនេះនោះ កន្លែងហ្នឹងឯងបោះឆ្នោត។

ប៊ុនថន: និយាយថាអត់មានប៉ះទ្រូសប្រាទ្រាំងអីទេ?

ហ៊ីយៈ ទេ រូបថតហ្នឹងនៅតើរូបថត កាលហ្នឹងអ៊ុនតាក់នោះ។

ប៊ុនថន: បាទ។

ហ៊ីយៈ នៅតើអត្តសញ្ញាណប័ណ្ណខ្ញុំនៅតើ ថតនៅកន្លែងហ្នឹងមានតើខ្ញុំទុកទាំងអស់ហ្នឹង។

ប៊ុនថន: ចឹងមីងនៅរហូតដល់?

ហ៊ីយៈ នៅដល់សព្វថ្ងៃតើ។

ប៊ុនថន: ចុះសមាហរណ៍កម្មហើយមីង?

ហ៊ីយៈ សមាហរណ៍កម្មហើយផ្ដាច់ខ្លួនហើយ?

ប៊ុនថនៈ បាទ ។

ហ៊ីយៈ នៅហ្នឹងដែរ ។

ប៊ុនថនៈ នៅម៉ាឡៃហ្នឹងដែរ?

ហ៊ីយៈ ចាស!នៅតែហ្នឹងឯងក្មួយមានទៅណាផង គ្មានប្រែប្រួលទេ ។

ប៊ុនថនៈ ចឹងមីងគេបើករបបឲ្យដល់ឆ្នាំណាបានឈប់?

ហ៊ីយៈ ទាល់តែផ្ដាច់ខ្លួន យើងផ្ដាច់ខ្លួនហើយបានឈប់ ។

ប៊ុនថនៈ ចឹងផ្ដាច់ខ្លួនហើយមីងធ្វើអីវិញ?

ហ៊ីយៈ ផ្ដាច់ខ្លួនហើយធ្វើនំបញ្ចុកលក់សើច... ។

ប៊ុនថនៈ ធ្វើនំបញ្ចុកលក់?

ហ៊ីយៈ លក់នៅក្នុងផ្សារ ហ្នឹងចាប់ផ្ដើមរកស៊ីហើយ ធ្វើនំបញ្ចុកលក់ត្រីលក់អីទៅណាស់ ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ ក្រោយមកបានទិញដីចំការបានហ្នឹង ក៏ធ្វើចំការទៅ ។

ប៊ុនថនៈ ចឹងមីងនៅហ្នឹងពេលណាបានគេចាយលុយវិញមីង?

ហ៊ីយៈ ចាយលុយតាំងពីជំនាន់វ៉ៃគ្នាក៏ចាយដែរ ។

ប៊ុនថនៈ ចាយលុយអីវិញ?

ហ៊ីយៈ ចាយលុយបាត ។

ប៊ុនថនៈ លុយបាត?

ហ៊ីយៈ ចាស!បើថាយើងចង់ទៅថៃចឹងទៅបើយើងអត់មានលុយយើងយកអង្ករទៅ ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ ដូចជាម្ហូបអីក៏បានដែរ ជាបន្លែអីក៏បានដែរយើងវិចអង្ករទៅ ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ យើងចាយជាមួយថៃហ្នឹងទៅ ថៃលក់បន្ថែមអីក៏មានដែរយើងដូចជាអង្ករទៅបើអត់លុយវិចអង្ករយកទៅចាយទៅ ។

ប៊ុនថនៈ បាទ!ចឹងចាយតែលុយថៃទេ?

ហ៊ីយៈ ចាស!ដល់ពេលនេះទៅបើចង់បានលុយចឹងអត់មានរកអីទេក្មួយ គ្រាន់តែថាយកអង្ករទៅលក់ឲ្យថៃទៅបានអង្កររមកហើយ ។

ប៊ុនថនៈ ចឹងចាយលុយតាំងពីសង្គ្រាមហ្នឹងមក?

ហ៊ីយៈ ចាស ។

ប៊ុនថន: ចឹងនិយាយថាក្រោយផ្តាច់ខ្លួនហើយបានចាប់ផ្តើមរកស៊ី?

ហ៊ីយៈ ចាស!ផ្តាច់ខ្លួនហើយបានមីងរកស៊ី ។

ប៊ុនថន: ចង់សួរមីងថាមុនពេលមីងផ្តាច់ខ្លួននិងផ្តាច់ខ្លួនហើយដូចថានៅហូបរបបបើកហើយក្រោយផ្តាច់ខ្លួនហ្នឹងមីង គិតថាការរស់នៅហ្នឹងជីវភាពអីរកហ្នឹងយ៉ាងម៉េចដែរ ពិបាកឬក៏?

ហ៊ីយៈ ទេ ក្មួយកាលពីមុនហូបអន្តរជ្ជក្រោយដែលរកស៊ីឯកជន ការហូបចុកការពិតទៅធម្មតារបស់គេ មិនទូលាយដូចកំលាំងយើងរកទេ ។

ប៊ុនថន: បាទ ។

ហ៊ីយៈ ក៏ប៉ុន្តែមិនទូលាយត្រង់ណា មិនទូលាយថាយើងវាអត់មានសេរីភាពរកស៊ីទៅឆ្ងាយទៅណាទៅណីបានណាស់ ។

ប៊ុនថន: បាទ ។

ហ៊ីយៈ ក៏ប៉ុន្តែក្រោយដែលផ្តាច់ខ្លួនហើយនេះ យើងមានសិទ្ធដើររកត្រង់ណាក៏បានដែរ កាលពីមុនយើងមិនទាន់ផ្តាច់ខ្លួនទៅឆ្ងាយខ្លាចមានសង្គ្រាមនៅផ្ទះ ។

ប៊ុនថន: បាទ ។

ហ៊ីយៈ ចឹងវាអត់មានទូលាយត្រង់កន្លែងហ្នឹងឯង យើងផ្តាច់ខ្លួនហើយយើងមានសិទ្ធទៅណាយើងអត់មានភ័យព្រួយអីទាំងអស់ ។

ប៊ុនថន: បាទ ។

ហ៊ីយៈ ចឹងបានថាវាគ្រាន់តែប៉ុណ្ណឹងទេ វាមានអីណាខុសគ្នា វាខុសថាវាស្រួលឲ្យយើងអត់ពិបាកគិតថ្ងៃនេះខ្លាចស្អែកខ្លាចអីទេ ។

ប៊ុនថន: ចឹងរាល់ថ្ងៃមីងមានកូនប៉ុន្មាននាក់មីង?

ហ៊ីយៈ រាល់ថ្ងៃមីងកូននៅតែមួយទេ ។

ប៊ុនថន: នៅកូនតែមួយទេ?

ហ៊ីយៈ ចាស!កូនប្រុស ។

ប៊ុនថន: កូនបង្កើតប៉ុន្មាននាក់?

ហ៊ីយៈ ៧នាក់ស្លាប់អស់៦ ។

ប៊ុនថន: ស្លាប់អស់៦?

ហ៊ីយៈ ចាស ។

ប៊ុនថន: នៅសល់តែម្នាក់?

ហ៊ីយៈ សល់តែមួយពៅគេ ។

ប៊ុនថនៈ ហើយមានគ្រួសារហើយនៅ?

ហ៊ីយៈ មានហើយកូន ប្រពន្ធវាដើរមិញ ។

ប៊ុនថនៈ កូនស្រីកូនប្រុសារ?

ហ៊ីយៈ កូនប្រុសារ ។

ប៊ុនថនៈ ស្លាប់អស់ច្រើនម៉េះ?

ហ៊ីយៈ ស្លាប់មិនដឹងជាយ៉ាងម៉េចទេ កើតមកបានបីបួនខែក៏ស្លាប់ទៅ៥ខែក៏ស្លាប់ពាក្យចាស់ថាយើងអារើសកូន ។

ប៊ុនថនៈ ចឹងនៅតែម្នាក់?

ហ៊ីយៈ ចាស! នៅតែមួយ ។

ប៊ុនថនៈ កូនមានគ្រួសារហើយ នៅតែពីរនាក់ពូ?

ហ៊ីយៈ ចាស! តែរាល់ថ្ងៃហ្នឹងមិនឲ្យបែកទៅណាទេ នៅទាំងអស់គ្នាហ្នឹង ។

ប៊ុនថនៈ កុំឲ្យស្វាត់?

ហ៊ីយៈ ម៉េចស្វាត់បែកទៅណាម៉េចកើត ។

ប៊ុនថនៈ ចុះថាទៅសៀមរាបនោះ?

ហ៊ីយៈ មកវិញហើយ មកវិញល្ងាចមិញទើបមក ។

ប៊ុនថនៈ ចឹងមីងខ្ញុំអត់មានសំនួរសួរមីងទេ មីងមានអីចង់សួរខ្ញុំវិញឬចង់បន្ថែមថាជីវិតមីងចងចាំជាងគេហើយវាជាការលំបាកឬងាយស្រួលអីដែលចងចាំ មីងចាំកន្លែងណាជាងគេមីង?

ហ៊ីយៈ មីងមិនមានអីផ្ដែផ្ដាំបងប្អូនទេ តែគ្រាន់តែថាយើងវាដុតទុក្ខដុតទោសហើយរាល់ថៃហ្នឹងរាល់ថ្ងៃនេះយើងជឿនលឿនហើយ ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ សម្ដេចហ្នឹងគាត់កសាងជឿនលឿនហើយឲ្យប្រជាជនហ្នឹងត្រេកអរខ្លាំងណាស់ ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ ការងារអី ក៏ជឿនលឿនទាំងអស់ហើយ ។

ប៊ុនថនៈ បាទ ។

ហ៊ីយៈ មិនពិបាកភ័យភិតទេ ។

ប៊ុនថនៈ ចឹងខ្ញុំអស់អីសួរមីងហើយ សូមអរគុណ ។

ហ៊ីយៈ ចាស ។

**«ចប់»**